ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារសម្រេចបានឆ្នាំ២០១៤
# និង ទិសដៅអនុវត្តបន្ត

គណៈកម្មការសិក្សាស្រាវជ្រាវទប់ស្កាត់ករណីសន្លប់ និង បញ្ហាគ្រោះថ្នាក់ការងារ
( ស.ទ.ប.ក )

បោះពុម្ពដោយ
បេឡាជាតិរបបសន្តិសុខសង្គម

អាសយដ្ឋាន ៖ អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ទី១
ខណ្ឌទួលគោក រាជធានីភ្នំពេញ
(ស្ថិតក្នុងបរិវេណ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ)

ទូរស័ព្ទបន្ទាន់ (Hotline) ៖ ១២៨៦

ទូរស័ព្ទសាកសួរព័ត៌មាន ៖ ០២៣ ៨៨ ២៤ ៣៤ / ០២៣ ៩៩ ៨៤ ១៧

គេហទំព័រ ៖ www.nssf.gov.kh

សារអេឡិចត្រូនិច ៖ www.info@nssf.gov.kh

ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារសម្រេចបានឆ្នាំ២០១៤
# និង ទិសដៅអនុវត្តបន្ត

រៀបចំដោយ គណៈកម្មការសិក្សាស្រាវជ្រាវទប់ស្កាត់ករណីសន្លប់
និងបញ្ហាគ្រោះថ្នាក់ការងារ នៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

បោះពុម្ពដោយ បេឡាជាតិរបបសន្តិសុខសង្គម

# មាតិកា


ឧបករណ៍វាស់ស្ទង់របស់គណៈកម្មការ ស.ទ.ប.ក........................................................ ០
របាយការណ៍បូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៤ និង ទិសដៅអនុវត្តបន្ត........... ១
ក. លទ្ធផលការងារសម្រេចបាន........................................................................... ១
១. ស្ថានភាពករណីកម្មករនិយោជិតសន្លប់......................................................... ១
១.១ អំពីមូលហេតុកម្មករនិយោជិតសន្លប់....................................................... ១
១.២ អំពីវិធានការដាក់ឱ្យនិយោជកកែលំអ...................................................... ៣
១.៣ ទិន្នន័យកម្មករនិយោជិតសន្លប់ឆ្នាំ២០១៤................................................. ៥
២. វិភាគទិន្នន័យកម្មករនិយោជិតសន្លប់ឆ្នាំ២០១៤.............................................. ១៦
២.១ មូលហេតុនៃកម្មករនិយោជិតសន្លប់........................................................ ១៦
២.២ រោងចក្រ និង កម្មករនិយោជិតសន្លប់ នៅតាមបណ្តារាជធានី-ខេត្ត..................... ១៦
៣. ការវិវត្តនៃទិន្នន័យ..................................................................................... ១៧
៣.១ ទិន្នន័យរោងចក្រ ក្នុងឆ្នាំ២០១៣ និង ឆ្នាំ២០១៤........................................ ១៧
៣.២ ទិន្នន័យកម្មករនិយោជិតសន្លប់ ក្នុងឆ្នាំ២០១៣ និង ឆ្នាំ២០១៤....................... ១៧
៣.៣ ប្រវត្តិទិន្នន័យរោងចក្រមានកម្មករនិយោជិតសន្លប់......................................... ១៨
៣.៤ ប្រវត្តិទិន្នន័យកម្មករនិយោជិតសន្លប់........................................................ ១៩
៣.៥ ការវិភាគទិន្នន័យជារួម.......................................................................... ២០
៣.៦ ទិន្នន័យរោងចក្រ និង កម្មករសន្លប់តាមឆ្នាំចាស់ បានកើតមានក្នុងឆ្នាំ២០១៤..... ២២
៤. វដ្តនៃកម្មករនិយោជិតសន្លប់.........................................................................២៣
៥. ការសិក្សាស្រាវជ្រាវ និង ការការពារករណីកម្មករនិយោជិតសន្លប់...............................២៣
៦. ការផ្សព្វផ្សាយអប់រំ.................................................................................... ២៦
ខ. បញ្ហាប្រឈម.............................................................................................. ៤២
គ. ដំណោះស្រាយ........................................................................................... ៤៣
ឃ. ការងារអនុវត្តបន្ត........................................................................................ ៤៣
ង. សេចក្តីសន្និដ្ឋាន......................................................................................... ៤៤
- ឯកសារយោង................................................................................................ ៤៥
- ទំនាក់ទំនង.................................................................................................. ៤៥

# ឧបករណ៍វាស់ស្ទង់របស់គណៈកម្មការ
# សិក្សាស្រាវជ្រាវទប់ស្កាត់ករណីសន្លប់ និង បង្ការគ្រោះថ្នាក់ការងារ (ស.ទ.ប.ក)



GasAlertMicro 5

(វាស់ $O_2$, CO, $H_2S$, $SO_2$, $CO_2$ ...)




Light Meter Extech

(វាស់កំរិតពន្លឺ)




Anemometer

(វាស់សីតុណ្ហភាព សំណើម និង ល្បឿនខ្យល់)




Sound Level Meter

(វាស់កំរិតសំលេង)




Oxymeters

(វាស់ចង្វាក់បេះដូង និង អុកស៊ីសែនក្នុងឈាម)

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងារសម្រេចបានឆ្នាំ២០១៤ និង ទិសដៅអនុវត្តបន្ត របស់គណៈកម្មការទប់ស្កាត់ករណីសន្លប់ និង បង្ការគ្រោះថ្នាក់ការងារ(ស.ទ.ប.ក)

ការរក្សាបាននូវស្ថិរភាពនយោបាយ និង សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៤ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង ការដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ នៃអាណត្តិរាជរដ្ឋាភិបាលនីតិកាលទី៥ បានទាក់ទាញវិនិយោគិនឱ្យមកវិនិយោគនៅកម្ពុជាយ៉ាងច្រើនលើគ្រប់វិស័យដោយបានបង្កើតការងារជូនដល់ប្រជាពលរដ្ឋទូទៅ បានជាច្រើនក្នុងមួយឆ្នាំៗ ។ តាមរយៈកំណើននៃការវិនិយោគទាំងក្នុងស្រុក និង មកពីបរទេសបានធ្វើឱ្យវិស័យសេដ្ឋកិច្ចកម្ពុជាមានការរីកចំរើនគ្រប់ផ្នែក ក្នុងនោះក៏មានផ្នែកកាត់ដេរសំលៀកបំពាក់ និង ផលិតស្បែកជើង ផងដែរ ។ យោងលើការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយទប់ស្កាត់ និង កាត់បន្ថយកម្មករនិយោជិតសន្លប់ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ជាសេនាធិការផ្ទាល់ មានតួនាទីជាអ្នកគ្រប់គ្រង និង ចាត់ចែងរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ បានបង្កើតគណៈកម្មការ ស.ទ.ប.ក នេះឡើង ដែលមានលេខាធិការដ្ឋាននៅ ប.ស.ស ។

ក្នុងឆ្នាំ២០១៤នេះ គណៈកម្មការស.ទ.ប.ក បានចុះទៅសម្របសម្រួលជួយសង្គ្រោះ និង ចាត់វិធានការនានាលើករណីកម្មករនិយោជិតសន្លប់ ដូចខាងក្រោម ៖

## ក. លទ្ធផលការងារសម្រេចបាន

### ១. ស្ថានភាពករណីកម្មករនិយោជិតសន្លប់

#### ១.១ អំពីមូលហេតុបណ្តាលឱ្យកម្មករនិយោជិតសន្លប់

ក្នុងឆ្នាំ២០១៤ នេះ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមាន ប.ស.ស សហការជាមួយគណៈកម្មការស.ទ.ប.ក បានចុះទៅតាមបណ្តារោងចក្រកាត់ដេរសំលៀកបំពាក់ និង ស្បែកជើង ដែលបានជួបឧប្បត្តិហេតុកម្មករនិយោជិតសន្លប់ ក្នុងនោះរកឃើញមូលហេតុ និង ចំណុចប្រឈមជាច្រើន ដូចខាងក្រោម៖

## ➢ អំពីលក្ខខណ្ឌការងារ និង លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ

### ❖ បញ្ហាគីមី

- ក្លិនបង្គន់សាយភាយចូលខ្សែចង្វាក់ផលិតកម្ម
- បំពង់ផ្សែងឡចំហាយរោងចក្រមានកំពស់ទាបដែលជាហេតុនាំឱ្យមានផ្សែងហុយចូលក្នុងអាគារផលិតកម្ម
- ធុំក្លិនស្អុយសាយភាយចេញពីអាគុយសាក
- ធុំក្លិនការបិទស្បែកជើងដែលទុកដាក់ និង ប្រើប្រាស់ខុសលក្ខណៈបច្ចេកទេស
- សាយភាយក្លិនថ្នាំបាញ់ (Spray U-90) ចូលក្នុងអាគារផលិតកម្ម
- ក្លិនផ្សែងដុតកង់ឡានហុយចូលអាគារផលិតកម្ម ដែលសហជីពជាអ្នកដុតដើម្បីធ្វើបាតុកម្ម
- ក្លិនកំទេចកំទីក្រណាត់ និង ធូលី
- កាកសំណល់ថ្នាំលាយពណ៌សម្រាប់បោះពុម្ពលើអាវរបស់រោងចក្រសាន់ថៃដែលនៅជាប់គ្នា
- កម្មករនិយោជិតមួយចំនួនមិនបានពាក់ម៉ាស់ និង ស្រោមដៃដើម្បីការពារ និងទប់ទល់នឹងក្លិនការបិទកាបូប
- ការជ្រាបឧស្ម័នចេញពីប្រព័ន្ធបំពង់របស់ឧស្ម័នធ្វើឱ្យភាយក្លិនទៅប៉ះនឹងកណ្តឹងសង្គ្រោះបន្ទាន់ ដែលធ្វើឱ្យសំលេងកណ្តឹងរោទិ៍ឡើង
- ផ្សែងម៉ាស៊ីនភ្លើងហុយពីរោងចក្រដទៃ
- ផ្សែងប្រេងម៉ាស៊ីន ត្រូវបានចម្រាញ់នៅមាត់ទន្លេ សម្រាប់ប្រើឡើងវិញ
- ផ្សែងដុតសម្រាម នៅក្បែររោងចក្រ

### ❖ បញ្ហារូបសាស្ត្រ (បរិយាកាសណ៍កំដៅ ក្តៅ និង ហប់)

- ទំហំអាគារមានប្រហោងរន្ធខ្យល់មិនបាន ១/៤ នៃផ្ទៃអាគារ
- ការរៀបចំប្រព័ន្ធខ្យល់ត្រជាក់មិនបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
- បំពាក់កង្ហារមិនបានគ្រប់គ្រាន់ ក្នុងអាគារផលិតកម្ម
- អាងស្តុកទឹកក្រោមដីប៉ែកខាងត្បូងក្នុងអាគារ B រោងចក្រ បាក់ស្រុត

### ❖ បញ្ហាចិត្តសាស្ត្រសង្គម

- ការតានតឹងអារម្មណ៍
- មានកម្មការិនីខ្យល់គរបណ្តាលឱ្យស្លាប់បាត់បង់ជីវិត ទើបធ្វើឱ្យកម្មករផ្សេងៗទៀតភិតភ័យ ស្លន់ស្លោ និង សន្លប់តៗគ្នា
- វិវាទការងារ (សហជីព និង សហជីព) បណ្តាលឱ្យមានកូដកម្ម បាតុកម្មដែលជាហេតុធ្វើឱ្យកម្មករក្នុងរោងចក្រចលាចលសន្លប់តៗគ្នា ។

### ❖ បញ្ហាវិទ្យាសាស្ត្ររៀបចំការងារ

- ការទុកដាក់សម្ភារៈក្រណាត់គរបាំងលំហូរខ្យល់ចេញចូល ។

❖ **បញ្ហាមេកានិច**

- ការអាក់ខានមិនបានជួលជុលកង្ហារដែលមិនដំណើរការ
- ផ្ទុះសេខ្សែភ្លើង បណ្តាលមកពីរបូតខ្ចៅម៉ូទ័រ ទើបធ្វើឱ្យខ្សែពានវាត់ត្រូវខ្សែភ្លើង របួចផ្ទុះឆ្លងចរន្តអគ្គិសនី

❖ **បញ្ហាជីវសាស្ត្រ**

- សុខភាពកម្មករនិយោជិតមួយចំនួន មានសភាពទន់ខ្សោយ (ខ្វះជាតិស្ករ...)
- ការផ្គត់ផ្គង់ចំណីអាហារថ្ងៃត្រង់មិនបានល្អ (គ្មានអនាម័យ និង គុណភាព)
- ចុកពោះ/រាគ ក្អួតចង្អោរ
- នាំគ្នាអត់ហូបអាហារពេលព្រឹក (ខ្ជិល និង គេងមិនគ្រប់គ្រាន់) ។

❖ **បញ្ហាការថែមម៉ោងធ្វើការ**

- ថែមម៉ោងច្រើនលើសពីគោលការណ៍អនុញ្ញាតរបស់ក្រសួង
- ថែមម៉ោងក្នុងមួយថ្ងៃ ២ម៉ោង ភាគច្រើនជាប្រចាំ
- ថែមម៉ោងក្នុងមួយថ្ងៃលើសពី២ម៉ោង គឺអាស្រ័យនឹងការបញ្ចេញទំនិញជាដើម

កត្តាថែមម៉ោងខាងលើ មកពីកម្មករនិយោជិតបង្ខំចិត្តថែមម៉ោងដោយសារចង់បានប្រាក់ឈ្នួលបន្ថែម ហើយម្តងម្កាលធ្វើឱ្យគាត់ទ្រោលការងារលែងបាន បូករួមនឹងការសម្រាកមិនបានគ្រប់គ្រាន់ ហូបអាហារមិនទៀងទាត់ និង គ្មានជីវជាតិ ជាហេតុបណ្តាលឱ្យកម្មករនិយោជិតសន្លប់ ។

## ១.២ អំពីវិធានការដាក់ឱ្យនិយោជកកែលំអ

ដើម្បីធានាការការពារសុខភាព និង សុវត្ថិភាពការងារ ពិសេសករណីកម្មករនិយោជិតសន្លប់ គណៈកម្មការស.ទ.ប.ក បានចុះទៅពិនិត្យអង្កេតស្វែងរកមូលហេតុ នឹងបានចាត់វិធានការជាបន្ទាន់ឱ្យម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាន ធ្វើការកែលំអ ដើម្បីទទួលបាននូវសុខដុមរមនា ក្នុងកន្លែងការងារ ដោយជំរុញឱ្យមានការកែលំអ ដូចតទៅ ៖

➢ **អំពីលក្ខខណ្ឌការងារ និង លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ**

❖ **ករណីបញ្ហាគីមី**

- សំអាតបង្គន់ជាប្រចាំ ដើម្បីកុំឱ្យក្លិនសាយភាយចូលខ្សែចង្វាក់ផលិតកម្ម
- តបំពង់ឡចំហាយឱ្យខ្ពស់ ដើម្បីកុំឱ្យផ្សែងហុយចូលអាគារផលិតកម្ម
- ត្រួតពិនិត្យការប្រើប្រាស់អាគុយសាកឱ្យបានត្រឹមត្រូវ និង ជាប្រចាំ
- រៀបចំទុកដាក់ និង ប្រើប្រាស់កាវឱ្យស្របតាមលក្ខណៈបច្ចេកទេស (ស្របតាមតារាងទិន្នន័យសុវត្ថិភាពគីមី)
- ការថ្នាំបាញ់ (Spray U-90) ចូលក្នុងអាគារផលិតកម្ម ត្រូវសំអាតក្លិនឱ្យអស់មុននឹងឱ្យកម្មករនិយោជិតចូលធ្វើការវិញ

- រៀបចំថង់ប្លាស្ទិច/ថង់ក្រណាត់ភ្ជាប់នឹងម៉ាស៊ីនដេរ ដើម្បីកុំឱ្យកំទេចកំទីក្រណាត់បង្កជាក្លិន និង ប៉ះពាល់ដល់ការដកដង្ហើម
- រៀបចំទុកដាក់ និង ប្រើប្រាស់កាកសំណល់តាមលក្ខណៈបច្ចេកទេស
- ណែនាំផ្សព្វផ្សាយការផ្តល់ និង ប្រើប្រាស់ឧបករណ៍ការពាររាងកាយជាប្រចាំក្នុងសកម្មភាពផលិតកម្ម
- ត្រួតពិនិត្យគ្រប់បំពង់បង្ហូរខ្យល់ចំហាយអ៊ុត ឬ ឧស្ម័ន ... ជាប់ជាប្រចាំ
- តបំពង់ផ្សែងម៉ាស៊ីនភ្លើងបន្ថែម ៦ម៉ែត្រ តាមលក្ខណៈបច្ចេកទេស
- ណែនាំកុំឱ្យចម្រាញ់ប្រេងម៉ាស៊ីនខុសបច្ចេកទេស ដែលនាំឱ្យផ្សែងហុយខ្លាំង
- ណែនាំកុំឱ្យដុតសម្រាម ដែលនាំឱ្យហុយចូលរោងចក្រ និង អាចបង្កអគ្គិភ័យ ។

❖ **ករណីបញ្ហារូបសាស្ត្រ**

- បំពាក់កង្ហារបន្ថែម, បំពាក់ប្រព័ន្ធបាញ់ទឹកស្រោចលើដំបូល
- ណែនាំឱ្យលាងសំអាតផ្លិតទឹកនៃប្រព័ន្ធខ្យល់ត្រជាក់តាមលក្ខណៈបច្ចេកទេស
- បើកប្រព័ន្ធខ្យល់ត្រជាក់៣០នាទី មុនកម្មករនិយោជិតចូលធ្វើការ ។

❖ **ករណីបញ្ហាចិត្តសាស្ត្រសង្គម**

- ពន្យល់ណែនាំអប់រំកុំឱ្យមានភាពតានតឹងអារម្មណ៍
- ផ្សព្វផ្សាយអប់រំពីគោលការណ៍ច្បាប់ និង បទប្បញ្ញត្តិនានា ។

❖ **ករណីបញ្ហាវិទ្យាសាស្ត្ររៀបចំការងារ**

- ណែនាំពីការរក្សាទុកដាក់សម្ភារៈក្រណាត់កុំឱ្យបាំងលំហូរខ្យល់ចេញចូល ។

❖ **ករណីបញ្ហាមេកានិច**

- ជួសជុលកង្ហារដែលមិនដំណើរការ និង បើកកង្ហាររក្សាលំហូរខ្យល់/សំណើម
- ត្រួតពិនិត្យឧបករណ៍ប្រើប្រាស់ ដែលប្រើប្រព័ន្ធអគ្គិសនី និង រៀបចំប្រព័ន្ធខ្សែភ្លើង តាមលក្ខណៈបច្ចេកទេស ។

❖ **ករណីបញ្ហាជីវសាស្ត្រ**

- ណែនាំកម្មករនិយោជិតបរិភោគអាហារមានអនាម័យ និង ជីវជាតិ
- ណែនាំកម្មករនិយោជិតឱ្យយល់ដឹងពីរបបអាហារទាំងបីក្រុម ។

❖ **ករណីការថែមម៉ោងធ្វើការ**

- ការថែមម៉ោងត្រូវគោរពតាមច្បាប់ស្តីពីការងារ
- ណែនាំកម្មករនិយោជិតពីអត្ថប្រយោជន៍នៃការសម្រាកឱ្យបានគ្រប់គ្រាន់ ដើម្បីធានាពីសុខភាពថាមពលក្នុងសកម្មភាពការងារថែមម៉ោង ។

## ១.៣ ទិន្នន័យកម្មករនិយោជិតសន្លប់ក្នុងឆ្នាំ២០១៤

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | ឈ្មោះ សកម្មភាពសេដ្ឋកិច្ច និង អាសយដ្ឋានរោងចក្រ | ចំនួន កម្មករ សរុប | ចំនួន កម្មករ គ្រោះថ្នាក់ | ភាគរយ | មូលហេតុ និង ការសន្និដ្ឋាន | អាការៈ គ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ១ | ២០/០១/២០១៤ | WANSHEN CLOTHING (CAMBODIA) Co., Ltd<br>- ផលិតសំលៀកបំពាក់<br>- ស.កន្ទោក ខ.ពោធិសែនជ័យ រាជធានីភ្នំពេញ | ៥១១ | ៣៣ | ៦.៤៥ % | - ការថែមម៉ោង<br>- ក្លិនបង្គន់ភាយចូល<br>- ឡចំហាយរោងចក្រនៅជាប់គ្នាហុយចូល<br>- បូករួមនឹងសុខភាពកម្មករនិយោជិតខ្សោយ | - ថប់ដង្ហើម<br>- ស្លន់ស្លោរ<br>- ភិតភ័យ |
| ២ | ២៧/០២/២០១៤ | CRISTAL MARTIN (CAMBODIA) Co., Ltd<br>- ផលិតសំលៀកបំពាក់<br>- ភ.វិហារសួគ៍ជើង ឃ.វិហារសួគ៍ ស.ខ្សាច់កណ្តាល ខេត្តកណ្តាល | ៣,០៨៦ | ១២៤ | ៤ % | - ធុំក្លិនស្អុយសាយភាយចេញពីអាគុយសាក<br>- ការថែមម៉ោង | - ឃីងជោង<br>- វិលមុខ<br>- ចង់ក្អួតចង្អោរ |
| ៣ | ២៧/០២/២០១៤ | SHIMANO (CAMBODIA) Co., Ltd<br>- ផលិតស្បែកជើង<br>- ឃ.ត្រពាំងគង ស.សំរោងទង ខេត្តកំពង់ស្ពឺ | ៩៥៥ | ២៧ | ២.៨២ % | - ការថែមម៉ោង<br>- ក្លិនការ | - ថប់ដង្ហើម<br>- វិលមុខ<br>- ក្អួតចង្អោរ<br>- ត្រជាក់ចុងដៃជើង |

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | ឈ្មោះ សកម្មភាពសេដ្ឋកិច្ច និង អាសយដ្ឋានរោងចក្រ | ចំនួន កម្មករ សរុប | ចំនួន កម្មករ គ្រោះថ្នាក់ | ភាគរយ | មូលហេតុ និង ការសន្និដ្ឋាន | អាការៈ គ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ៤ | ១៣/០៣/២០១៤<br>១៤/០៣/២០១៤ | CAMBO KOTOP Ltd<br>-ផលិតសំលៀកបំពាក់<br>-ផ្លូវជាតិលេខ៤ ស.ចោមចៅ<br>ខ.ពោធិ៍សែនជ័យ រាជធានីភ្នំពេញ | ២,៥៤៦ | ១៦ + ១ ស្លាប់<br>៣៨ | ២.១២ % | -កម្មការិនី ជីង សុផឹម បានខ្យល់គរស្លាប់ ទើបបណ្ដាលឱ្យកម្មករនិយោជិតផ្សេង ទៀតភ្ញាក់ផ្អើល ហើយសន្លប់តៗគ្នា<br>-ការថែមម៉ោង | -ភិតភ័យ<br>-រំជួលចិត្តខ្លាំង<br>-ស្លន់ស្លោ<br>-ត្រជាក់ចុងដៃជើង |
| ៥ | ០១/០៤/២០១៤ | CALLISTO APPAREL (CAMBODIA) Co., Ltd<br>-ផលិតសំលៀកបំពាក់<br>-ភ.ស្រែរាជ ស.សំរោងក្រោម<br>ខ.ពោធិសែនជ័យ រាជធានីភ្នំពេញ | ៣៧០ | ០៧ | ១.៨៩% | -ធុំក្លិនផ្សែងដុតកង់ឡានហុយចូលអាគារ ផលិតកម្ម ដែលសហជីពស្មារតីកម្មករខ្មែរ ជាអ្នកដុតធ្វើបាតុកម្ម | -ថប់ដង្ហើម<br>-ស្លន់ស្លោ<br>-ភិតភ័យ<br>-ត្រជាក់ចុងដៃជើង |
| ៦ | ០១/០៤/២០១៤<br>០២/០៤/២០១៤ | NEW WINDE (CAMBODIA) GARMENT Co., Ltd<br>-ផលិតសំលៀកបំពាក់<br>-ភ.ទួលពង្រ ស.ចោមចៅ<br>ខ.ពោធិសែនជ័យ រាជធានីភ្នំពេញ | ១,២៥០ | ១៦<br>៤៧ | ៥% | -ធុំក្លិនបាញ់ថ្នាំ (Spray U-90) អស់ ០៦ កំប៉ុង នៅត្រង់បន្ទប់ជួសជុល ហើយភាយ ចូលក្នុងអាគារផលិតកម្ម<br>-ការថែមម៉ោង | -ថប់ដង្ហើម<br>-ក្អួតចង្អោរ<br>-ឈឺក្បាល<br>-វិលមុខ |

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | ឈ្មោះ សកម្មភាពសេដ្ឋកិច្ច និង អាសយដ្ឋានរោងចក្រ | ចំនួន កម្មករ សរុប | ចំនួន កម្មករ គ្រោះថ្នាក់ | ភាគរយ | មូលហេតុ និង ការសន្និដ្ឋាន | អាការៈ គ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ៧ | ០២/០៤/២០១៤<br>០៣/០៤/២០១៤ | DAQIAN TEXTILE (CAMBODIA) Co., Ltd<br>-ផលិតសំលៀកបំពាក់<br>-ភ.ត្រពាំងថ្លឹង ស.ចោមចៅ<br>ខ.ពោធិសែនជ័យ រាជធានីភ្នំពេញ | ៣,៨១៥ | ៣៨<br>៥៣ | ២.៣៨% | -ផ្គត់ផ្គង់អាហារថ្ងៃត្រង់មិនបានល្អ (មិនមានអនាម័យ និង គុណភាព)<br>-ការថែមម៉ោង<br>** រោងចក្រ DAQIAN TEXTILE (CAMBODIA) Co., Ltd និង SHENZHOU (CAMBODIA) Co., Ltd មានម្ចាស់តែមួយ | -ចុកពោះ<br>-ក្អួត<br>-ឈឺក្បាល វិលមុខ<br>-ត្រជាក់ចុងដៃជើង |
| ៨ | ០៣/០៤/២០១៤ | SHENZHOU (CAMBODIA) Co., Ltd<br>-ផលិតសំលៀកបំពាក់<br>-ស.ស្ទឹងមានជ័យ ខ.មានជ័យ រាជធានីភ្នំពេញ (ក្នុងសួនឧស្សាហកម្មវត្តស្លែង:១) | ២,១១២ | ២២ | ១.០៤% | | |
| ៩ | ០៤/០៤/២០១៤ | COCOVOL APPAREL (CAMBODIA) Co., Ltd<br>-ផលិតសំលៀកបំពាក់<br>-ភ.ព្រៃព្រីងខាងត្បូង ស.ចោមចៅ<br>ខ.ពោធិសែនជ័យ រាជធានីភ្នំពេញ | ៧២៩ | ២៥ | ៣.៤២% | -ការធ្វើបាតុកម្មទាមទារអាហារថ្ងៃត្រង់ ដែលរោងចក្រឈប់ផ្តល់ជូន នៅខាងក្រៅរោងចក្រ ដែលនាំឱ្យកម្មករនិយោជិតនៅក្នុងរោងចក្រចលាចល ហើយសន្លប់តៗគ្នា<br>-ការធ្វើការថែមម៉ោង | -ស្លន់ស្លោ<br>-ភិតភ័យ<br>-ត្រជាក់ចុងដៃជើង |

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | ឈ្មោះ សហគ្រាសសេដ្ឋកិច្ច និង អាសយដ្ឋានរោងចក្រ | ចំនួន កម្មករ សរុប | ចំនួន កម្មករ គ្រោះថ្នាក់ | ភាគរយ | មូលហេតុ និង ការសន្និដ្ឋាន | អាការៈ គ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ១០ | ៣០/០៤/២០១៤ | WINNING DRAGON LEATHER WARE ( CAMBODIA ) Co., Ltd<br>-ផលិតសំលៀកបំពាក់<br>-ផ្លូវលេខ៤១ ភ.ដូនកែវ ឃ.សែនដី ស.សំរោងទង ខេត្តកំពង់ស្ពឺ | ៤៨៣ | ១៩ | ៣.៩៣% | -បរិយាការណ៍កំដៅ ក្តៅ ហប់<br>-ការថែមម៉ោង | -ស្លន់ស្លោរ<br>-ភិតភ័យ<br>-ត្រជាក់ចុងដៃជើង |
| ១១ | ២៩/០៥/២០១៤ | WOORIE GARMENTS<br>-ផលិតសំលៀកបំពាក់<br>-ភ.កន្ទោកខាងជើង ស.កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ | ១,៤៨០ | ៩៥ | ៦.៩៥% | -បរិយាការណ៍កំដៅ ក្តៅ ហប់<br>-តានតឹងអារម្មណ៍ ( ពេលដឹងថាម្តាយឈឺ )<br>-ការថែមម៉ោង | -ស្លន់ស្លោរ<br>-ភិតភ័យ<br>-ត្រជាក់ចុងដៃជើង |
| | ៣០/០៥/២០១៤ | | | ០៨ | | | |
| ១២ | ៣០/០៥/២០១៤ | Huey Chuen ( Cambodia ) Co., Ltd<br>-ផលិតស្បែកជើង<br>-ភូមិជ្រោយអំពិល សង្កាត់ក្បាលកោះ ខណ្ឌមានជ័យ រាជធានីភ្នំពេញ | ១,៣០៦ | ២៨ | ៦.៦៦% | -បរិយាការណ៍កំដៅ ក្តៅ ហប់<br>-កម្មករនិយោជិតម្នាក់ចុកពោះ<br>-ការថែមម៉ោង | -ស្លន់ស្លោរ<br>-ភិតភ័យ<br>-ត្រជាក់ចុងដៃជើង |
| | ០៣/០៦/២០១៤ | | | ៣៣ | | | |
| | ០៩/០៦/២០១៤ | | | ២៦ | | | |

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | ឈ្មោះ សកម្មភាពសេដ្ឋកិច្ច និង អាសយដ្ឋានរោងចក្រ | ចំនួន កម្មករ សរុប | ចំនួន កម្មករ គ្រោះថ្នាក់ | ភាគរយ | មូលហេតុ និង ការសន្និដ្ឋាន | អាការៈ គ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ១៣ | ០២/០៦/២០១៤ | JIUN YE ( CAMBODIA ) CO., Ltd<br>-ផលិតសំលៀកបំពាក់<br>-ភ.ស្ពានពោធិ៍ ឃ.សេដ្ឋី<br>ស.សាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង | ៣,៦១៥ | ៣៧ | ១% | -បរិយាការណ៍កំដៅ ក្តៅ ហប់<br>-កម្មករនិយោជិតម្នាក់កាច់ដៃកាច់ជើង (ខ្វះជាតិស្ករ និង កាល្យូម)<br>-ការថែមម៉ោង | -ស្លន់ស្លោរ<br>-ភិតភ័យ<br>-ត្រជាក់ចុងដៃជើង |
| ១៤ | ១៣/០៦/២០១៤<br>១៦/០៦/២០១៤ | FORTUNE RICH ( CAMBODIA )<br>-ផលិតសំលៀកបំពាក់<br>-ផ្លូវឌួងងៀបឲ ភ.ដំណាក់ធំ៣<br>ស.ស្ទឹងមានជ័យ ខ.មានជ័យ<br>រាជធានីភ្នំពេញ | ៦៤០ | ៦៩<br>៤៥ | ១៧.៨១% | -សម្ភារៈក្រណាត់បាំងលំហូរខ្យល់ចេញចូល<br>-កម្មករនិយោជិតមានសុខភាពទន់ខ្សោយ<br>-ការថែមម៉ោង | -ស្លន់ស្លោរ<br>-ភិតភ័យ<br>-ត្រជាក់ចុងដៃជើង |
| ១៥ | ២៧/០៦/២០១៤<br>០១/០៧/២០១៤<br>២៩/០៧/២០១៤ | T & K Garment Industry CO., Ltd<br>-ផលិតខោខូវប៊យ<br>-ភ.ទួលពង្រ ស.ចោមចៅ<br>ខ.ពោធិ៍សែនជ័យ រាជធានីភ្នំពេញ | ១,២៥០ | ១៥<br>៥<br>៣ | ១.៨៤% | -បរិយាការណ៍កំដៅ ក្តៅ ហប់<br>-កម្មករនិយោជិតម្នាក់កាច់ដៃកាច់ជើង (ជំងឺផ្ទាល់ខ្លួន)<br>-ក្លិនស្អុយចេញពីបង្គន់<br>-ក្លិនកំទិចក្រណាត់<br>-ការថែមម៉ោង<br>-ក្លិនផ្សែងឈៀមពីរោងចក្រចាងស៊ឹងដែលជួបឧបទ្ទហេតុអគ្គីភ័យ | -ថប់ដង្ហើម<br>-ឈឺក្បាល វិលមុខ<br>-ញឹងញោង<br>-ចង្អោរ<br>-ត្រជាក់ចុងដៃជើង |

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | ឈ្មោះ សកម្មភាពសេដ្ឋកិច្ច និង អាសយដ្ឋានរោងចក្រ | ចំនួន កម្មករ សរុប | ចំនួន កម្មករ គ្រោះថ្នាក់ | ភាគរយ | មូលហេតុ និង ការសន្និដ្ឋាន | អាការៈ គ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ១៦ | ២៨/០៦/២០១៤<br>៣០/៦/២០១៤<br>០១/៧/២០១៤ | GINGKO (CAMBODIA) CO., Ltd<br>-ផលិតអាវធំបុរស<br>-ភ.ព្រៃផ្តៅ ស.ច្រកម្ទេស ក្រុងបាវិត ខេត្តស្វាយរៀង | ១,១៦៤ | ៤៥<br>៣០<br>៣២ | ៩.១៩% | -បរិយាការណ៍កំដៅ ក្តៅ ហប់<br>-សុខភាពកម្មករនិយោជិតទន់ខ្សោយ | -ពិបាកដកដង្ហើម<br>-ឈឺក្បាល វិលមុខ<br>-ភិតភ័យ<br>-ត្រជាក់ចុងដៃជើង |
| ១៧ | ១៨/០៧/២០១៤ | Wonderful Garments (Cambodia) Ltd<br>ផលិតសំលៀកបំពាក់<br>-ស.ព្រែកប្រា ខ.ច្បារអំពៅ រាជធានីភ្នំពេញ | ២១៩ | ៨ | ៣.៦៥% | -កាកសំណល់ថ្នាំលាយពណ៌សម្រាប់បោះពុម្ពលើអាវរបស់រោងចក្រសាន់វៃ ដែលនៅជាប់គ្នា | -ពិបាកដកដង្ហើម<br>-ឈឺក្បាល វិលមុខ ធីងធោង |
| ១៨ | ២៥/០៧/២០១៤<br>២៦/០៧/២០១៤ | PAK SHUN KNITTING FACTORY LTD<br>-ផលិតសំលៀកបំពាក់<br>-ស.ចាក់អង្រែក្រោម ខ.មានជ័យ រាជធានីភ្នំពេញ | ១,២៨០ | ៦<br>៥ | ០.៨៥% | -បញ្ហាសុខភាពផ្ទាល់ខ្លួន (សម្រាក, ហូបអាហារមិនទៀងទាត់ និង បញ្ហាកត្តាផ្លូវចិត្ត)<br>-ការថែមម៉ោងធ្វើការជាប្រចាំ | -ឈឺក្បាល វិលមុខ<br>-ទន់ដៃទន់ជើង |
| ១៩ | ២៦/០៧/២០១៤<br>២៨/០៧/២០១៤ | SIXPLUS INDUSTRY CO., LTD<br>-ផលិតសំលៀកបំពាក់<br>-ផ្លូវជាតិលេខ៦ ភូមិកណ្តាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល | ២,២២៦ | ១៦៤<br>៦៩ | ១០.៤៦% | -ក្លិនស្អុយខាងក្រៅរោងចក្រ<br>-ការថែមម៉ោងធ្វើការជាប្រចាំ | -វិលមុខ ធីងធោង<br>-ថប់ដង្ហើម<br>-ណែនទ្រូង<br>-ទន់ដៃទន់ជើង |

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | ឈ្មោះ សកម្មភាពសេដ្ឋកិច្ច និង អាសយដ្ឋានរោងចក្រ | ចំនួន កម្មករ សរុប | ចំនួន កម្មករ គ្រោះថ្នាក់ | ភាគរយ | មូលហេតុ និង ការសន្និដ្ឋាន | អាការៈ គ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ២០ | ០១/០៨/២០១៤ | HENIEMO ( CAMBODIA ) HOME TEXTILE Co., Ltd<br>- ផលិតកំរាលពូក<br>- តំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ ភ.ពូធឿង ឃ.បិតត្រាំង ស.ព្រៃនប់ ខេត្តព្រះសីហនុ | ២៣០ | ៣៦ | ១៥.៦៥% | -ផ្តើមចេញពីការឈឺក្បាលបន្តិចបន្តួច ដោយគ្មានគ្រូពេទ្យ/គិលានុប្បដ្ឋាយិការ ផ្តល់ការសង្គ្រោះបឋមនៅក្នុងគិលានដ្ឋាន របស់រោងចក្រ<br>-ការបិទ/បើកកង្ហារបឺតខ្យល់ចេញចូល របស់រោងចក្រមិនបានទៀងទាត់ធ្វើឱ្យ បរិយាការណ៍កំដៅ ក្តៅ ហប់ | - ឈឺក្បាល វិលមុខ<br>- ធីងធោង<br>- ចង្អោរ និង<br>- ទន់ដៃទន់ជើង |
| ២១ | ០៧/០៨/២០១៤ | TENG XUN LIMITED<br>- ផលិតកាបូប<br>- ផ្លូវលេខ៤១ ឃ.សែនដី ស.សំរោងទង ខេត្តកំពង់ស្ពឺ | ៧៦២ | ២៦ | ៣.៤១% | -ផ្តើមចេញពីការកម្មការិនីមានផ្ទៃពោះ មានអាការៈឈឺក្បាលវិលមុខ ធីងធោង កម្មករនិយោជិតក៏ភិតភ័យសន្លប់តៗគ្នា<br>-កម្មករនិយោជិតភាគច្រើនមិនបានពាក់ ម៉ាស់ និង ស្រោមដៃសម្រាប់ការពារនឹង ក្លិនការ | - ឈឺក្បាល វិលមុខ<br>- ធីងធោង<br>- ចង្អោរ និង<br>- ទន់ដៃទន់ជើង |
| ២២ | ១៥/០៨/២០១៤<br>១៨/០៨/២០១៤ | Newpex Co., Ltd<br>- ផលិតកាបូប<br>- បណ្តោយផ្លូវជាតិលេខ៣ ភ.ទឹកថ្លា ស.ក្រាំងពង្រ ខ.ដង្កោ រាជធានីភ្នំពេញ | ៩៥០ | ២៩<br>៦ | ៣.៦៨% | -ផ្តើមចេញពីកម្មការិនីនៅក្នុងរោងចក្រ នីមួយៗខាងលើ តែ ២ នាក់ ក្នុង១រោងចក្រដូចគ្នាៗ មានអាការៈ ឈឺក្បាលវិលមុខ ធីងធោង ទន់ដៃ/ជើង ទើបធ្វើឱ្យកម្មការិនីផ្សេងៗទៀតភិតភ័យ | - ឈឺក្បាល វិលមុខ<br>- ធីងធោង<br>- ចង្អោរ និង<br>ទន់ដៃទន់ជើង |

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | ឈ្មោះ សកម្មភាពសេដ្ឋកិច្ច និង អាសយដ្ឋានរោងចក្រ | ចំនួន កម្មករ សរុប | ចំនួន កម្មករ គ្រោះថ្នាក់ | ភាគរយ | មូលហេតុ និង ការសន្និដ្ឋាន | អាការៈ គ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ២៣ | ១៥/០៨/២០១៤ | ACCASETTE<br>- ផលិតសំលៀកបំពាក់<br>- បណ្តោយផ្លូវជាតិលេខ៣ ភ.ទឹកថ្លា ស.ក្រាំងពង្រ ខ.ដង្កោ រាជធានីភ្នំពេញ | ១,៣០០ | ៣០ | ២.៣០% | និង មានអាការៈស្រដៀងគ្នា សន្លប់តៗគ្នា<br>-ចំពោះបញ្ហានៅក្នុងអាគារផលិតកម្ម គឺ មានតែអាគារទី២ របស់រោងចក្រ Newpex Co., Ltd ប៉ុណ្ណោះ មាន បរិយាកាសណ៍កំដៅ ក្តៅ ហប់ និង កង្ហារ មួយចំនួនធំមិនដំណើរការ ។<br>(បញ្ហាកម្មករនិយោជិតសន្លប់ នៅក្នុង តំបន់សួនឧស្សាហកម្មវ៉ឺឡន:២ មាន ៥ រោងចក្រ រួមមាន៖ រោងចក្រ Newpex Co., Ltd, រោងចក្រACCASETTE, រោងចក្រ Moha 1, 2 and 3, រោងចក្រ DongDu Textile Co., Ltd, រោងចក្រPapillion Textile Co., Ltd ) | |
| ២៤ | ១៥/០៨/២០១៤ | Moha 1, 2 and 3<br>- ផលិតសំលៀកបំពាក់<br>- បណ្តោយផ្លូវជាតិលេខ៣ ភ.ទឹកថ្លា ស.ក្រាំងពង្រ ខ.ដង្កោ រាជធានីភ្នំពេញ | ២,៩០០ | ២៥ | ០.៨៦% | | |
| ២៥ | ១៥/០៨/២០១៤<br>១៨/០៨/២០១៤ | DongDu Textile Co., Ltd<br>- ផលិតសំលៀកបំពាក់<br>- បណ្តោយផ្លូវជាតិលេខ៣ ភ.ទឹកថ្លា ស.ក្រាំងពង្រ ខ.ដង្កោ រាជធានីភ្នំពេញ | ១,៧៩៥ | ៤០<br>៥៥ | ៥.២៩% | | |

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | ឈ្មោះ សកម្មភាពសេដ្ឋកិច្ច និង អាសយដ្ឋានរោងចក្រ | ចំនួន កម្មករ សរុប | ចំនួន កម្មករ គ្រោះថ្នាក់ | ភាគរយ | មូលហេតុ និង ការសន្និដ្ឋាន | អាការៈ គ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ២៦ | ១៥/០៨/២០១៤<br>១៨/០៨/២០១៤ | Papillion Textile Co., Ltd<br>- ផលិតសំលៀកបំពាក់<br>- បណ្តោយផ្លូវជាតិលេខ៣ ភ.ទឹកថ្លា ស.ក្រាំងពង្រ ខ.ដង្កោ រាជធានីភ្នំពេញ | ១,២៨០ | ១៥<br>៧៩ | ៧.៣៩% | | |
| ២៧ | ២៨/០៨/២០១៤ | YAZAKI (Cambodia) Productions Co., Ltd<br>- ផលិតខ្សែរភ្លើងក្នុងរថយន្ត<br>- ឃ.ប៉ាក់ខ្លង ស.មណ្ឌលសេមា ខេត្តកោះកុង | ១,៧០០ | ៧ | ០.៤១% | -ការជ្រាបឧស្ម័នចេញពីប្រព័ន្ធ ធ្វើឱ្យបំពង់របស់ឧស្ម័នភាយក្លិន សម្លេងកណ្តឹងប្រកាសអាសន្នក៏រោទិ៍ឡើង | -ភិតភ័យ ស្លន់ស្លោរ<br>-ថប់ដង្ហើម ធីងជោង<br>-ទន់ដៃ ទន់ជើង |
| ២៨ | ០៥/០៩/២០១៤ | M & V International Manufacturing Ltd<br>- ផលិតសំលៀកបំពាក់<br>- ភ.ត្រពាំងចិក្សា ស.កំពង់ឆ្នាំង ក.កំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង | ៣,៨០០ | ១១ | ០.២៨% | -ផ្ទុះសេខ្សែភ្លើងបណ្តាលមកពីរបូតខ្ទៅម៉ូទ័រ ទើបធ្វើឱ្យខ្សែពានវាត់ត្រូវខ្សែភ្លើង រួចផ្ទុះ ឆ្លងចរន្តអគ្គិសនី | -ភិតភ័យ ស្លន់ស្លោរ<br>-ទន់ដៃ ទន់ជើង |
| ២៩ | ០២/១០/២០១៤<br>០៣/១០/២០១៤ | TOWA Industry (Cambodia) Co., Ltd<br>- ផលិតផ័ត្រ<br>- ស.បាទី ក.បារិត ខេត្តស្វាយរៀង | ១,៥៦៩ | ៥៨<br>២៦ | ៥.៣៥% | -កត្តាចិត្តសាស្ត្រសង្គម<br>-បរិយាកាសណ៍កំដៅ ក្តៅ ហប់ | -ភិតភ័យ ស្លន់ស្លោរ<br>-ចង់ក្អួត ថប់ដង្ហើម<br>-ទន់ដៃ ទន់ជើង |

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | ឈ្មោះ សកម្មភាពសេដ្ឋកិច្ច និង អាសយដ្ឋានរោងចក្រ | ចំនួន កម្មករ សរុប | ចំនួន កម្មករ គ្រោះថ្នាក់ | ភាគរយ | មូលហេតុ និង ការសន្និដ្ឋាន | អាការៈ គ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ៣០ | ០៣/១០/២០១៤ | JIFA S. OK Garment (Cambodia) Co., Ltd<br>- ផលិតសំលៀកបំពាក់<br>- ស.បាទី ក.បារិត ខេត្តស្វាយរៀង | ៣៨៥ | ៦២ | ១៦.១% | -កត្តាចិត្តសាស្ត្រសង្គម ដោយសារដឹងព័ត៌មានថាមានរោងចក្រនៅក្បែរគ្នាសន្លប់ជាបន្តបន្ទាប់ | -ភិតភ័យ ស្លន់ស្លោរ<br>-ទន់ដៃ ទន់ជើង |
| ៣១ | ២១/១០/២០១៤ | NISHIKU ENTERPRISE CO., LTD<br>- ផលិតសំលៀកបំពាក់<br>- ឃ.ពត់សរ ស.បាទី ខេត្តតាកែវ | ១,៩៥០ | សន្លប់ ៣ និង របួស ៥ នាក់ | ០.១៥% | -អាងស្តុកទឹកក្រោមដីប៉ែកខាងត្បូងក្នុងអាគារB បានបាក់ស្រុត បណ្តាលឱ្យកម្មករនិយោជិត រងរបួសស្រាល ធ្លាក់ចូលអាងទឹក ៥នាក់ និង ទន់ដៃទន់ជើង ៣នាក់ ។ | -ភិតភ័យ ស្លន់ស្លោរ<br>-ទន់ដៃ ទន់ជើង |
| ៣២ | ២៤/១០/២០១៤ | DIN HAN ENTERPRISE CO., LTD<br>- ផលិតសំលៀកបំពាក់<br>- ផ្លូវខ្នងរៀប ស.ស្ទឹងមានជ័យ ខ.មានជ័យ រាជធានីភ្នំពេញ | ១,៥០០ | ៤២ | ២.៨% | -សុខភាពកម្មការិនីចុះខ្សោយ<br>-អត់ហូបអាហារពេលព្រឹក និង សម្រាកមិនគ្រប់គ្រាន់ | -វិលមុខ ឈឺងពោះ<br>-ទន់ដៃ ទន់ជើង |
| ៣៣ | ១៨/១១/២០១៤ | JTH TEXTILE (CAMBODIA) INC<br>- ផលិតសំលៀកបំពាក់<br>- បណ្តោយផ្លូវជាតិលេខ៤ ស.កំបូល ខ.ពោធិ៍សែនជ័យ រាជធានីភ្នំពេញ | ២,៧៧៥ | ៤៥ | ១.៦២% | -ផ្សែងម៉ាស៊ីនភ្លើងហុយពីរោងចក្រដទៃ | -វិលមុខ ឈឺងពោះ<br>-ថប់ដង្ហើម ឈឺក្បាល<br>-ទន់ដៃ ទន់ជើង |

| ល.រ | កាលបរិច្ឆេទ គ្រោះថ្នាក់ | ឈ្មោះ សហគ្រាសសេដ្ឋកិច្ច និង អាសយដ្ឋានរោងចក្រ | ចំនួន កម្មករ សរុប | ចំនួន កម្មករ គ្រោះថ្នាក់ | ភាគរយ | មូលហេតុ និង ការសន្និដ្ឋាន | អាការៈ គ្រោះថ្នាក់ |
|---|---|---|---|---|---|---|---|
| ៣៤ | ២១/១១/២០១៤<br>២២/១១/២០១៤ | Great Union ( Cambodia ) Garment Co., Ltd<br>- ផលិតសំលៀកបំពាក់<br>- ស.ចាក់អង្រែក្រោម ខ.មានជ័យ រាជធានីភ្នំពេញ | ៩៥០ | ៨<br>១៥ | ២.៤២% | -ធុំក្លិនផ្សែងប្រេងម៉ាស៊ីនដែលចូលទឹក ត្រូវបានចម្រាញ់ដុតនៅមាត់ប្រាំងទន្លេ សម្រាប់ប្រើឡើងវិញ ( កម្មករសាឡង់បូម ខ្សាច់បានដុត )<br>-ធុំក្លិនផ្សែងសម្រាមដុតនៅជិតរោងចក្រ | - ថប់ដង្ហើម ឈឺក្បាល<br>- ទន់ដៃ ទន់ជើង |
| សរុប ៣៤ រោងចក្រ | | | ៩២,៨៨៣ | ១,៨០៦ | ៣.៤១% | | |

# ២. វិភាគទិន្នន័យកម្មករនិយោជិតសន្លប់ ក្នុងឆ្នាំ២០១៤

## ២.១ មូលហេតុនៃកម្មករនិយោជិតសន្លប់

✓ មូលហេតុនៃកម្មករនិយោជិតសន្លប់ទាំង ៣៤ រោងចក្រកាត់ដេរ និង ផលិតស្បែកជើង




✓ មូលហេតុនៃកម្មករនិយោជិតសន្លប់ទាំង៣៤ រោងចក្រ ធៀបនឹងរោងចក្រកាត់ដេរ និង ផលិតស្បែកជើង ដែលបានចុះបញ្ជិកានៅ ប.ស.ស ទាំង ១,០៧៤ រោងចក្រ




## ២.២ រោងចក្រ និង កម្មករនិយោជិតសន្លប់ នៅតាមបណ្តារាជធានី-ខេត្ត

- ចំនួនរោងចក្ររងការសន្លប់ទាំង ៣៤ រោងចក្រ និង




- ចំនួនកម្មករនិយោជិតសន្លប់ ១,៨០៦ នាក់



## ៣.ការវិភាគនៃទិន្នន័យ

### ៣.១ ទិន្នន័យរោងចក្រ ក្នុងឆ្នាំ២០១៣ និង ឆ្នាំ២០១៤

| ល.រ | រាជធានី/ខេត្ត | ឆ្នាំ២០១៣ | ឆ្នាំ២០១៤ |
|---|---|---|---|
| | សរុបរួម | ១៥ | ៣៤ |
| ១ | រាជធានីភ្នំពេញ | ៣ | ២១ |
| ២ | ខេត្តកណ្តាល | ៥ | ២ |
| ៣ | ខេត្តកំពង់ស្ពឺ | ៣ | ៣ |
| ៤ | ខេត្តកោះកុង | ១ | ១ |
| ៥ | ខេត្តកំពង់ឆ្នាំង | - | ២ |
| ៦ | ខេត្តស្វាយរៀង | ២ | ៣ |
| ៧ | ខេត្តព្រះសីហនុ | - | ១ |
| ៨ | ខេត្តកំពង់ចាម | ១ | - |
| ៩ | ខេត្តតាកែវ | - | ១ |




### ៣.២ ទិន្នន័យកម្មករនិយោជិតសន្លប់ ក្នុងឆ្នាំ២០១៣ និង ឆ្នាំ២០១៤

| ល.រ | រាជធានី/ខេត្ត | ឆ្នាំ២០១៣ | ឆ្នាំ២០១៤ |
|---|---|---|---|
| | សរុបរួម | ៨២៣ | ១,៨០៦ |
| ១ | រាជធានីភ្នំពេញ | ១៥៤ | ១,០៣០ |
| ២ | ខេត្តកណ្តាល | ៤៣២ | ៣៥៧ |
| ៣ | ខេត្តកំពង់ស្ពឺ | ៦៨ | ៧២ |
| ៤ | ខេត្តកោះកុង | ១៩ | ៧ |
| ៥ | ខេត្តកំពង់ឆ្នាំង | - | ៤៨ |
| ៦ | ខេត្តស្វាយរៀង | ១២៥ | ២៥៣ |
| ៧ | ខេត្តព្រះសីហនុ | - | ៣៦ |
| ៨ | ខេត្តកំពង់ចាម | ២៥ | - |
| ៩ | ខេត្តតាកែវ | - | ៣ |




## ៣.៣ ប្រវត្តិទិន្នន័យរោងចក្រមានកម្មករនិយោជិតសន្លប់ តាមបណ្ដារាជធានី/ខេត្ត

| ល.រ | ឆ្នាំ / រាជធានី/ខេត្ត | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|
| | សរុបរួម | ១២ | ២៤ | ១៥ | ៣៤ |
| ១ | រាជធានីភ្នំពេញ | ៩ | ១៥ | ៣ | ២១ |
| ២ | ខេត្តកណ្ដាល | - | ៣ | ៥ | ២ |
| ៣ | ខេត្តកំពង់ស្ពឺ | ២ | ២ | ៣ | ៣ |
| ៤ | ខេត្តកោះកុង | - | - | ១ | ១ |
| ៥ | ខេត្តកំពង់ឆ្នាំង | ១ | ១ | - | ២ |
| ៦ | ខេត្តស្វាយរៀង | - | ២ | ២ | ៣ |
| ៧ | ខេត្តព្រះសីហនុ | - | ១ | - | ១ |
| ៨ | ខេត្តកំពង់ចាម | - | - | ១ | - |
| ៩ | ខេត្តតាកែវ | - | - | - | ១ |



## ៣.៤ ប្រវត្តិទិន្នន័យកម្មករនិយោជិតសន្លប់ តាមបណ្តារាជធានី/ខេត្ត

| ល.រ | រាជធានី/ខេត្ត ឆ្នាំ | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|
| | សរុបរួម | ១,៩៧៣ | ១,៦៨៦ | ៨២៣ | ១,៨០៦ |
| ១ | រាជធានីភ្នំពេញ | ១,៤៦០ | ៦៦០ | ១៥៤ | ១,០៣០ |
| ២ | ខេត្តកណ្តាល | - | ១៥១ | ៤៣២ | ៣៥៧ |
| ៣ | ខេត្តកំពង់ស្ពឺ | ៣៥០ | ៤៦៤ | ៦៨ | ៧២ |
| ៤ | ខេត្តកោះកុង | - | - | ១៩ | ៧ |
| ៥ | ខេត្តកំពង់ឆ្នាំង | ១៦៣ | ៣៤ | - | ៤៨ |
| ៦ | ខេត្តស្វាយរៀង | - | ១២៦ | ១២៥ | ២៥៣ |
| ៧ | ខេត្តព្រះសីហនុ | - | ២៥១ | - | ៣៦ |
| ៨ | ខេត្តកំពង់ចាម | - | - | ២៥ | - |
| ៩ | ខេត្តតាកែវ | - | - | - | ៣ |



## ៣.៨ ការវិភាគប្រវត្តិទិន្នន័យជារួម

| ល.រ | បរិយាយ | ឆ្នាំ២០១១ | ឆ្នាំ២០១២ | ឆ្នាំ២០១៣ | ឆ្នាំ២០១៤ |
|---|---|---|---|---|---|
| ១ | រោងចក្រជួបបញ្ហាសន្លប់ | ១២ | ២៤ | ១៥ | ៣៤ |
| ២ | កម្មករសន្លប់ | ១,៩៧៣ | ១,៦៨៦ | ៨២៣ | ១,៨០៦ |
| ៣ | កម្មករមិនបានសន្លប់ក្នុងរោងចក្រជួបបញ្ហាសន្លប់ | ២៤,៩០៨ | ៣៣,៦៤៨ | ៣៤,៣៤៨ | ៥២,៨៨៣ |
| ៤ | រោងចក្រកាត់ដេរ/ស្បែកជើងបានចុះបញ្ជិកា ប.ស.ស | ៦៤៣ | ៨៨២ | ៩៦០ | ១,០៧៥ |
| ៥ | កម្មករកាត់ដេរ/ស្បែកជើងបានចុះបញ្ជិកា ប.ស.ស | ៤៥៩,៨៣៧ | ៥៥២,០៧២ | ៦១៧,៨១៤ | ៦៥៩,១៥៨ |
| ៦ | ផលធៀបរវាងល.រ ១ និង ៤ | ១.៨៦% | ២.៧២% | ១.៥៦% | ៣.១៦% |
| ៧ | ផលធៀបរវាងល.រ ២ និង ៥ | ០.៤២% | ០.៣០% | ០.១៣% | ០.២៥% |
| ៨ | ផលធៀបរវាងល.រ ២ និង ៣ | ៧.៩២% | ៥.០១% | ២.៤០% | ៣.៤១% |







៣/. ផលធៀបរវាង រោងចក្រជួបបញ្ហាសន្លប់
និង រោងចក្រកាត់ដេរ/ស្បែកជើង បានចុះបញ្ជិកា ប.ស.ស
៤.00%
៣.00%
២.00%
១.00%
0.00%
១.៨៦%
២.៧២%
១.៥៦%
៣.១៦%
ឆ្នាំ២០១១
ឆ្នាំ២០១២
ឆ្នាំ២០១៣
ឆ្នាំ២០១៤


៤/. ផលធៀបរវាង កម្មករជួបបញ្ហាសន្លប់
និង កម្មករកាត់ដេរ/ស្បែកជើង បានចុះបញ្ជិកា ប.ស.ស
0.៥0%
0.៤0%
0.៣0%
0.២0%
0.១0%
0.00%
0.៤២%
0.៣0%
0.១៣%
0.២៥%
ឆ្នាំ២០១១
ឆ្នាំ២០១២
ឆ្នាំ២០១៣
ឆ្នាំ២០១៤


៥/. ផលធៀបរវាង កម្មករជួបបញ្ហាសន្លប់
និង កម្មករមិនបានសន្លប់ក្នុងរោងចក្រជួបបញ្ហាសន្លប់
១0.00%
៨.00%
៦.00%
៤.00%
២.00%
0.00%
៧.៩២%
៥.00%
២.៤0%
៣.៤១%
ឆ្នាំ២០១១
ឆ្នាំ២០១២
ឆ្នាំ២០១៣
ឆ្នាំ២០១៤

## ៣.៦ ទិន្នន័យរោងចក្រ និង កម្មករសន្លប់តាមឆ្នាំចាស់ ប្រានកើតមានក្នុងឆ្នាំ២០១៤

| ល.រ | ឆ្នាំ | រោងចក្រជួបបញ្ហាសន្លប់ | | | កម្មករសន្លប់ | | |
|---|---|---|---|---|---|---|---|
| | | រោងចក្រសន្លប់ | រោងចក្រសន្លប់មាននៅក្នុងឆ្នាំ២០១៤ | សរុប | កម្មករសន្លប់ | កម្មករសន្លប់មាននៅក្នុងឆ្នាំ២០១៤ | សរុប |
| ១ | ២០១៤ | ៣៤ | | | ១,៨០៦ | | |
| ២ | ២០១៣ | ១៣ | ២ | ១៥ | ៧៧១ | ៥២ | ៨២៣ |
| ៣ | ២០១២ | ១៧ | ៧ | ២៤ | ១,៤២៨ | ២៥៨ | ១,៦៨៦ |
| ៤ | ២០១១ | ១០ | ២ | ១២ | ១,៥៧៤ | ៣៩៩ | ១,៩៧៣ |

ក្នុងឆ្នាំ២០១១, ឆ្នាំ២០១២ និង ឆ្នាំ២០១៣ មានរោងចក្រ និង កម្មករសន្លប់ ដែលកើតមានជាថ្មីនៅក្នុងឆ្នាំ២០១៤ ទៀត គឺមាន ១១រោងចក្រ និង កម្មករសន្លប់ ៧០៩ នាក់ ដូចលម្អិតខាងក្រោម ៖

- ឆ្នាំ២០១៣ មាន ២ រោងចក្រ និង កម្មករសន្លប់ ៥២ នាក់ ដែលកើតជាថ្មីក្នុងឆ្នាំ២០១៤ មាន៖

  ១- រោងចក្រ Dong Du Textile (Cambodia) Co., Ltd កាត់ដេរសម្លៀកបំពាក់ ស្ថិតនៅផ្លូវជាតិលេខ៣ ភូមិទឹកថ្លា ស.ក្រាំងពង្រ ខ.ដង្កោ រាជធានីភ្នំពេញ មានកម្មករសន្លប់ ៧ នាក់

  ២- រោងចក្រ WANSHEN CLOTHING (CAMBODIA) Co., Ltd ផលិតសំលៀកបំពាក់ ស្ថិតនៅ ស.កន្ទោក ខ.ពោធិ៍សែនជ័យ រាជធានីភ្នំពេញ មានកម្មករសន្លប់ ៤៥ នាក់

- ឆ្នាំ២០១២ មាន ៧ រោងចក្រ និង កម្មករសន្លប់ ២៥៨ នាក់ ដែលកើតជាថ្មីក្នុងឆ្នាំ២០១៤ មាន៖

  ១- ក្នុងសួនឧស្សាហកម្មវឌ្ឍនៈ ២ មាន *៤ រោងចក្រ* គឺរោងចក្រ NEWPEX Co., Ltd ផលិតកាបូបក្រណាត់, MOHA 1&2 Co., Ltd កាត់ដេរ, DUNG DO Co., Ltd កាត់ដេរ, PAPILION កាត់ដេរ មានកម្មករសន្លប់រួមគ្នាទាំងអស់ ១៣៨ នាក់

  ២- រោងចក្រ M&V international Manufacturing កាត់ដេរសម្លៀកបំពាក់ ស្ថិតនៅ ស.កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង មានកម្មករសន្លប់ ៣៤ នាក់

  ៣- រោងចក្រ SIXPLUS INDUSTRY កាត់ដេរសម្លៀកបំពាក់ ស្ថិតនៅផ្លូវជាតិលេខ៦ ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្ដាល មានកម្មករសន្លប់ ៧២ នាក់

  ៤- រោងចក្រ Huey Chien (Cambodia) Corp ផលិតស្បែកជើង ស្ថិតនៅផ្លូវវេងស្រេង រាជធានីភ្នំពេញ មានកម្មករសន្លប់ ១៤ នាក់

- ឆ្នាំ២០១១ មាន ២ រោងចក្រ និង កម្មករសន្លប់ ៣៩៩ នាក់ ដែលកើតជាថ្មីក្នុងឆ្នាំ២០១៤ មាន៖

  ១- រោងចក្រ M&V international Manufacturing កាត់ដេរសម្លៀកបំពាក់ ស.កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង មានកម្មករសន្លប់ ១៦៣ នាក់

  ២- រោងចក្រ Huey Chien (Cambodia) Corp ផលិតស្បែកជើង ស្ថិតនៅផ្លូវវេងស្រេង រាជធានីភ្នំពេញ មានកម្មករសន្លប់ ២៣៦ នាក់

## ៤. វដ្តនៃកម្មករនិយោជិតសន្លប់

★ ក្រាហ្វិចវដ្តនៃកម្មករនិយោជិតសន្លប់ មានពីរវដ្ត




❖ **វដ្តទី១**

- ពីខែមករាដល់ខែមេសាជារដូវដែលរោងចក្រទទួលបានការបញ្ជាទិញទំនិញថ្មី (បង្កើនសកម្មភាពផលិត)
  - បង្កើនការបន្ថែមម៉ោង ដើម្បីទុករយៈពេលសំរាកបស់កម្មករនិយោជិតពេលបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឱ្យបានយូរ
  - ជារដូវក្ដៅ និង ការសម្រាក(ដំណេក) មានរយៈពេលខ្លី ។
- ខែឧសភា និង ខែមិថុនា មិនសូវមានបញ្ហាកម្មករនិយោជិតសន្លប់ ។

❖ **វដ្តទី២**

- ពីខែកក្កដាដល់ខែតុលាជារដូវដែលរោងចក្រទទួលបានការបញ្ជាទិញទំនិញបន្ថែម (បង្កើនសកម្មភាពផលិត)
  - បង្កើនការបន្ថែមម៉ោង ដើម្បីទុករយៈពេលសំរាកបស់កម្មករនិយោជិតនាពេលបុណ្យភ្ជុំបិណ្ឌឱ្យបានយូរ
  - ជារដូវវស្សា ដកស្ទូង ច្រូតកាត់ និងការសម្រាក(ដំណេក) មានរយៈពេលខ្លី ។
- ខែវិច្ឆិកា និង ខែធ្នូ មិនសូវមានបញ្ហាកម្មករនិយោជិតសន្លប់ ។

## ៥. ការសិក្សាស្រាវជ្រាវ និង ការការពារករណីកម្មករនិយោជិតសន្លប់

Mass Psychogenic illness គឺជាជំងឺមួយប្រភេទដែលគេសំដៅលើជំងឺ Mass hysteria ជំងឺនេះត្រូវបានគេរកឃើញប្រហែល៦០០ឆ្នាំមុនមកហើយ ។វាជាជំងឺដែលមានលក្ខណៈកម្រជួបប្រទះក្នុងអំឡុងពេលសិក្សា ជំងឺនេះកើតឡើងនៅក្នុងរោងចក្រឧស្សាហកម្មមួយចំនួនក្នុងប្រទេសអង់គ្លេស បារាំង អាល្លឺម៉ង់ អ៊ីតាលី រុស្ស៊ី សហរដ្ឋអាមេរិច និងសាំងហ្គាពួរ ...។

Mass Psychogenic illness "MPI" = ជំងឺហ្វូងមនុស្សមានអារម្មណ៍ខ្លាំងក្លា

- M = Mass (ក្រុមមនុស្ស ឬ ហ្វូងមនុស្ស)
- P = Psychogenic (អារម្មណ៍ខ្លាំងក្លា)
- I = illness (ជំងឺ)
- Mass Hysteria (ជំងឺស្នេហ៍ហ្វូង)

នៅពេលដែលមនុស្សនៅក្នុងក្រុមចាប់ផ្តើមគិតថា ពួកគេបានឆ្លងជំងឺ ដែលមានគ្រោះថ្នាក់ ដូចជា៖ មេរោគមួយ ឬ ក៏ជាតិពុលដែលបង្កើតដោយអតិសុខុមប្រាណ ។ ពួកគេអាចមានរោគសញ្ញាឈឺក្បាល វិលមុខ ក្អួតចង្អោរ ថប់ដង្ហើម សុខភាពខ្សោយ មានអារម្មណ៍ទន់ដៃទន់ជើងលែងដឹងខ្លួន។ប្រសិនបើមានមនុស្សច្រើននៅក្នុងក្រុមចាប់ផ្តើមមានអារម្មណ៍ថាឈឺនៅពេលតែមួយ យើងអាចសន្និដ្ឋានថាពួកគេអាចមានជំងឺ Mass Psychogenic illness ។ ហើយជំងឺប្រភេទនេះ ច្រើនកើតឡើងលើក្រុមសិស្សសាលា និង ក្រុមកម្មករ ។ នៅពេលខ្លះជំងឺ Mass Psychogenic illness ក៏ត្រូវបានគេហៅថាជំងឺ Mass hysteria ឬ Epidemic hysteria ( ជំងឺស្នេហ៍ហ្វូង )។

ក. ក្នុងឆ្នាំ ១៩៩៩ សិស្សអនុវិទ្យាល័យនៃប្រទេសប៊ែលហ្សិក បានផ្ទុះឡើងនូវជំងឺ MPI ដែលបង្កឱ្យមានជនរងគ្រោះចំនួន ១២២ នាក់ ត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យ។ ភាគច្រើននៃជនរងគ្រោះគឺជាមនុស្សស្រី ។

- ការសន្និដ្ឋានលើកដំបូងគឺ បណ្តាលមកពីពុលភេសជ្ជៈ Coca Cola
- តែក្រោយការពិនិត្យដោយមន្ទីរពិសោធន៍ឯករាជ្យលើផលិតផល CocaCola រួចហើយ បានបញ្ជាក់ថាគ្មានសារជាតុគីមី ដែលបង្កឱ្យមានរោគសញ្ញាទាក់ទងនឹងជំងឺ MPI នោះ ទេ
- អ្នកជំនាញផ្នែកសុខាភិបាលបានបញ្ចប់សេចក្តីសន្និដ្ឋានថា វាជាការរីករាលដាលឆ្លងមកពីជំងឺ MPI ។

ខ. មន្ទីរពិសោធន៍នៃប្រទេសសាំងហ្គាពួរបានធ្វើការសិក្សាលើការរីករាលដាលនៃជំងឺ MPI ក្នុងរោងចក្រជាច្រើនក្នុងប្រទេសនៅចន្លោះឆ្នាំ១៩៧៣ រហូតដល់ ១៩៧៨ ។ ក្រោយការសិក្សាបានបង្ហាញលទ្ធផលថា ៖

- កម្មករនិយោជិតមានអាការៈភ័យខ្លាច និង ភ្លេចភ្លាំងស្មារតី
- កម្មករនិយោជិតមានអារម្មណ៍ថាត្រជាក់ ( ខ្លួនប្រាណ )
- កម្មករនិយោជិតមានអារម្មណ៍ស្ពឹកស្រពន់
- កម្មករនិយោជិតចាប់ផ្តើមសន្លប់
- ជំងឺនេះភាគច្រើនកើតឡើងលើស្ត្រី

គ. ក្នុងឆ្នាំ១៩៧៩ រោងចក្រស្បែកជើងមួយនៃសហរដ្ឋអាមេរិកបានផ្ទុះឡើងនូវជំងឺ MPI នាយកដ្ឋានសុខភាពនៃប្រទេសសហរដ្ឋអាមេរិក បានរៀបចំគម្រោងស៊ើបអង្កេតលើឧស្សាហកម្ម ៖

- ដោយការសាកសួរលើកម្មករនិយោជិតចំនួន ៥០-៧៥ នាក់ (ដែលបានឆ្លងនូវជំងឺនេះ)
- លទ្ធផលបានបង្ហាញថាកម្មករនិយោជិតមានរោគសញ្ញាដូចជា ៖ ឈឺក្បាល វិលមុខ ក្អួតចង្អោរ ថប់ ដង្ហើម និងមានអារម្មណ៍ទន់ដៃទន់ជើង ដោយមូលហេតុធំក្លិនចម្លែកនូវនឹងកន្លែងធ្វើការ
- មូលហេតុបណ្តាលឱ្យកើតឡើងនូវជំងឺនេះបណ្តាលមកពី ៖ បរិស្ថានជុំវិញខ្លួនមានភាពស្មុគស្មាញក្នុងការងារ ( Job stress ) និង ភាពស្មុគស្មាញនៅក្នុងជីវិត ( Life stress ) ។

**ការរីករាលដាលឆ្លងនេះនឹងមានការស្រាកស្រាន្តទៅវិញក្នុងរយៈពេលប្រហែល១សប្តាហ៍ ។**

✓ **មូលហេតុបង្កឱ្យមានការផ្ទុះឡើងនូវជំងឺ MPI**

នៅពេលដែលមានបុគ្គលណាមួយមានអាការៈឈឺក្បាល វិលមុខ ក្អួតចង្អោរ ថប់ដង្ហើម និង មានអារម្មណ៍ទន់ដៃទន់ជើង ហើយអ្នករួមការងារដែលនៅក្បែរជនរងគ្រោះ គិតថាខ្លួនបានឆ្លងនូវជំងឺនេះ ក៏មានអាការៈដូចគ្នានឹងជនរងគ្រោះដែរ ជាអាទិ៍ ៖

- សន្លប់តគ្នា
- ភាពស្មុគស្មាញចិត្ត ( Job stress and Life stress )
- ការសាយភាយក្លិនមិនល្អ
- ការសាយភាយនូវជាតិពុល
- បរិស្ថានមិនល្អ
- អគ្គិភ័យ ( ផ្សែង )
- ពុលសារជាតិគីមី
- ខ្វះអុកស៊ីសែន ។ល។

✓ **រោគសញ្ញា**

- ឈឺក្បាល វិលមុខ ចង្អោរ( ការតើ ) ចុកពោះ ក្អក អស់កម្លាំងហេវហត់ ងងុយគេង
- ឈឺ/ក្តៅបំពង់ក ដកដង្ហើមដង្ហក់ៗ ឬ ពិបាកដកដង្ហើម ក្តៅក្នុងភ្នែក តឹងណែនដើមទ្រូង

✓ **ដំណោះស្រាយ**

- ជម្លៀសមនុស្សចេញពីទីកន្លែងដែលមានការផ្ទុះឡើងនូវជំងឺ
- ថែទាំអ្នកជំងឺម្នាក់ៗ ដោយមានការពិនិត្យពិច័យពីគ្រូពេទ្យ និង ប្រាប់ទៅពួកគាត់ថា ( ពួកគាត់អត់មានជំងឺអ្វីធ្ងន់ធ្ងរទេ )
- ថែរក្សា ឬ ជម្លៀសមនុស្សដែលមានអារម្មណ៍ថាឈឺ ឱ្យនៅឆ្ងាយពីតំបន់ជ្រួលច្របល់ និង មានសំពាធ
- បំបែកក្រុមមនុស្សមានជំងឺ និង គ្មានជំងឺឱ្យនៅដាច់ដោយឡែកពីគ្នា
- បំបែកក្រុមមនុស្សពីមានចំនួនច្រើនឱ្យនៅចំនួនតិច ( ជៀសវាងការប្រមូលផ្តុំគ្នា )
- ធ្វើការត្រួតពិនិត្យតាមលក្ខណៈបច្ចេកទេស នៅទីកន្លែងដែលមានផ្ទុះឡើងនូវជំងឺ
- ព្យាយាមធ្វើឱ្យក្រុមកម្មករនិយោជិតជឿថា ទីកន្លែងនោះមានសុវត្ថិភាព និង ត្រលប់ទៅធ្វើការជាធម្មតា ( ក្រោយការត្រួតពិនិត្យចប់ )
- ធ្វើរោគវិនិច្ឆ័យលើប្រភេទជំងឺ និង រោគសញ្ញាផ្សេងៗ
- ត្រួតពិនិត្យមើលកំរិតអុកស៊ីសែន និង បរិស្ថានជុំវិញ
- ត្រួតពិនិត្យរកសារជាតុគីមី ដែលអាចមានផលប៉ះពាល់ដល់សុខភាព
- ព្យាយាមរកមនុស្ស ដែលកើតជំងឺនេះមុនគេ នៅកន្លែងដែលមានផ្ទុះឡើងនូវជំងឺនេះ
- ធ្វើការកាត់បន្ថយលើការព្យាបាលមួយចំនួនដែលមិនមានសារៈសំខាន់

យោងតាមគេហទំព័រ ៖ **http://en.m.wikipedia.org/wiki/mass_psychogenic_illness**

## ៦. ការផ្សព្វផ្សាយអប់រំ

ការផ្សព្វផ្សាយអប់រំនេះ បាននិងកំពុងរៀបចំឡើងតាំងពីធមាសទី២ឆ្នាំ២០១២ មក ដែលមាន ប.ស.ស នៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ជាអ្នកគ្រប់គ្រងការចំណាយ ក្នុងទិសដៅបង្ការគ្រោះថ្នាក់ការងារ ដោយលើកកម្ពស់លក្ខខណ្ឌការងារ លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ ពិសេសករណីកម្មករនិយោជិតសន្លប់ ។ ក្នុងកិច្ចប្រជុំផ្សព្វផ្សាយអប់រំនេះ គណៈកម្មការស.ទ.ប.ក ក៏មានឯកសារពាក់ព័ន្ធមួយចំនួន ដូចជា៖

- ការធ្វើបទបង្ហាញស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវទប់ស្កាត់ករណីសន្លប់និងវិធានការបង្ការគ្រោះថ្នាក់ការងារ ៖
  - លក្ខខណ្ឌការងារ
  - លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ
  - អត្ថប្រយោជន៍របបសន្តិសុខសង្គម
  - សុវត្ថិភាពចរាចរណ៍លើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត

**សម្រាប់ផ្នែកលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ**

✓ **ស្ត្រី ឬ បុរសដែលត្រូវការថាមពលច្រើនរួមមាន អ្នកចំការ អ្នកស្រែ អត្តពលករ ចំនួន ២៤០០ កាឡូរី/១ថ្ងៃ**

| ល.រ | មុខអាហារ | កាឡូរី | បរិយាយ |
|---|---|---|---|
| ១ | បាយ | ៧២០ | ៦០ ក្រ (១២ ស្លាបព្រាបាយ) |
| ២ | បន្លែ | ២៤០ | ៤០ ក្រ (៦ ស្លាបព្រាបាយ) |
| ៣ | ផ្លែឈើ | ... | ៥ ផ្លែ (៥ ចំណិត) |
| ៤ | សាច់មាន់ គោ ជ្រូក ត្រី ស៊ុត មឹក កំពិស | ១៨០ | ១២ ក្រ (១២ ស្លាបព្រាសម្ល) |
| ៥ | ទឹកដោះគោ | ... | ១ កែវ (២០០ ml) |
| ៦ | ត្រីឆ្អឹងតូចៗ (ត្រីលិញ ឬ ត្រីរៀល) | ៣០ | ១៥ ក្រ (២ ស្លាបព្រាសម្ល) |

កំណត់សំគាល់ ៖

- ១ស្លាបព្រាបាយ មានប្រហែល ៦០ក្រ
- ១ស្លាបព្រាបាយដំណើបស្មើនឹង២ស្លាបព្រាបាយធម្មតា
- ១ស្លាបព្រានំបញ្ចុកស្មើនឹង ៦០ក្រ
- ១បន្ទះនំប៉ុងស្មើនឹង ៣០ក្រ
- ១ស្លាបព្រាបាយនៃបន្លែស្មើនឹង ៤០ក្រ
- ១ស្លាបព្រាសម្លស្មើនឹង ១៥ក្រសាច់
- ១ចំណិតផ្លែឈើនៅទីនេះគេចាត់ទុកស្មើនឹងចេក១ផ្លែ ក្រូច១ផ្លែ សាវម៉ាវ៤ត្របែកមួយចំហៀង ផ្លែល្ហុង និង ម្នាស់ គេគិតថាពុះ១ផ្លែជា៦ចំណិត ។

### ✓ ការសង្គ្រោះបឋមមុនពេលបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ (ករណីគ្រោះថ្នាក់ស្រាល)

១. ការពិនិត្យមើលដង្ហើមចេញ ចូល

- ត្រូវពិនិត្យមើលជាប្រញាប់ថាខ្យល់មានចេញចូលតាមច្រមុះ តាមមាត់របស់ជនរងគ្រោះដែរ ឬទេ ?
- ប្រសិនបើជនរងគ្រោះសន្លប់បាត់ស្មារតី ហើយដេកផ្ងារនោះ អាចថប់ដង្ហើមបាន ដោយសារអណ្តាតរបស់គេរមូរចូលទៅក្នុងបំពង់ក ហើយធ្វើឱ្យស្ទះខ្យល់ដកដង្ហើម
- អាស្រ័យបែបនេះ បើជនរងគ្រោះសន្លប់ ត្រូវដាក់ឱ្យដេកផ្អៀង មុខចុះក្រោម ត្រូវមានការប្រុងប្រយ័ត្ន ប្រសិនបើគេអាចមានរបួសនៅក ។

២. ការដកដង្ហើមសិប្បនិម្មិត (គ្មានដង្ហើម)

- ប្រសិនបើជនរងគ្រោះគ្រាន់តែដួល ត្រូវទ្រកដោយដៃម្ខាង ហើយដៃម្ខាងទៀតដាក់លើថ្ងាស
- ចាប់ភ្ញោកក្បាល ជនរងគ្រោះទៅក្រោយឱ្យខ្លាំងតាមដែលអាចធ្វើទៅបាន
- យកមាត់ច្បាមរន្ធច្រមុះ ឬ ខ្ទប់រន្ធច្រមុះ (យកមាត់ និង មាត់ជនរងគ្រោះ ច្បាមរន្ធច្រមុះ ឬ ខ្ទប់រន្ធច្រមុះដោយបឺតផ្លុំខ្យល់តាមនេះ)
- ត្រូវសម្លឹងមើលទ្រូងរបស់ជនរងគ្រោះ ហើយកាលណាឃើញកំរើកនោះមានន័យថា សួតចាប់ផ្តើមទទួលយកខ្យល់ហើយ
- បន្តធ្វើចលនាបឺតផ្លុំបែបនេះក្នុងចន្លោះរយៈពេលប្រាំវិនាទីម្តង
- បន្តធ្វើការដកដង្ហើមសិប្បនិម្មិតរហូតទាល់តែជនរងគ្រោះចាប់ផ្តើមដកដង្ហើម ឬ បុគ្គលិកពេទ្យមកដល់ ។



៣. ការឃាត់ឈាម

- ប្រសិនបើជនរងគ្រោះមានហូរឈាម ត្រូវព្យាយាមឃាត់ឈាមដោយច្របាច់ខ្ទប់មុខរបួស និង ដាក់ដៃជើងអ្នករបួសសណ្តូបត្រង់ ។



៤. ការបង្ការការគាំងបេះដូង

- ការភ័យតក់ស្លុតចំពោះគ្រោះថ្នាក់ធ្ងន់ធ្ងរអាចបណ្តាលឱ្យស្លាប់បាន ប៉ុន្តែប្រការនេះយើងអាចបង្ការបាន៖
  - ដំបូងត្រូវពិនិត្យមើលថាជនរងគ្រោះនៅមានដង្ហើម ឬ អត់
  - បន្ទាប់មកត្រូវបង្ការការភ័យតក់ស្លុតដោយផ្តេកជនរងគ្រោះទៅចំហៀង
  - ស្រាយបន្ធូរសម្លៀកបំពាក់ដែលចងរឹតតឹង

- ដណ្តាប់ភួយឱ្យជនរងគ្រោះ
- កុំឱ្យអ្វីទៅជនរងគ្រោះផឹកឱ្យសោះលើកលែងតែមានបញ្ជាពីគ្រូពេទ្យ
- ការពារជនរងគ្រោះពីពន្លឺព្រះអាទិត្យផ្ទាល់
- យកទឹកផ្សើមបប្ចូរមាត់ និង អណ្តាតជនរងគ្រោះបើចាំបាច់







៥. របួស មុត រលាត់

- របួសភាគច្រើនច្រើនតែកើតចេញពីគ្រោះថ្នាក់ដោយសារមុត រលាត់
- ប្រសិនបើមុត និង រលាត់មានភាពស្រាលៗ សើៗ ដំបូងត្រូវឃាត់ឈាម បន្ទាប់មកត្រូវលាងសំអាតមុតរបួសដោយប្រុងប្រយ័ត្ន ។ ក្រោយពេលសំអាតរួចហើយត្រូវរុំមុខរបួសដោយក្រណាត់ស្បៃស្អាត
- ជានិច្ចកាលរបួសធ្ងន់ និង មុតជ្រៅត្រូវព្យាបាលដោយវេជ្ជបណ្ឌិត ក្នុងករណីបែបនេះ ការសង្គ្រោះបន្ទាន់គឺគ្រាន់តែជួយដាក់ និង រុំមុខរបួសតែប៉ុណ្ណោះ ។

៦. ការរលាក

- ប្រសិនបើសម្លៀកបំពាក់មនុស្សម្នាក់ត្រូវភ្លើងឆេះវិធីដ៏ល្អប្រសើរដើម្បីពន្លត់ភ្លើងគឺឱ្យជនរងគ្រោះប្រមៀលខ្លួននៅលើកំរាលឥដ្ឋ ឬ នៅក្នុងភួយ
- ក្រោយពន្លត់ភ្លើងរួចហើយ ត្រូវយកទឹកត្រជាក់ទៅចាក់លើកន្លែងរលាក ត្រូវគ្របមុខរលាកហើយនាំយកជនរងគ្រោះទៅមន្ទីរពេទ្យជាបន្ទាន់

- ដាច់ខាតមិនត្រូវប្រើម្សៅ ខ្លាញ់ប៉រ ក្រែម អាល់កុល អ៊ីយ៉ូត ឬ ជាតិដូចខាងលើនេះ ទៅលើមុខរលាកឱ្យសោះ ។ ដាច់ខាតកុំបំបែកពងទឹកនៅលើមុខរលាកឱ្យសោះ ។



៧. របួសដោយសារវត្ថុធាតុកាត់ស្បែក



- ប្រសិនបើនរណាម្នាក់ធ្វើឱ្យកំពប់ទឹកអាស៊ីដ ឬ ជាតិអាកាឡាំងទៅលើស្បែករបស់បងប្អូន នោះបងប្អូនត្រូវលាងទឹកភ្លាម ។ បន្ទាប់មកមុខរបួសដែលបណ្តាលមកពីការកាត់ស្បែកដោយសារវត្ថុរាវ កាត់ស៊ីស្បែកណាមួយច្រើនតែមានសភាពអាក្រក់ជាងអ្វីដែលយើងមើលមិនឃើញ
- អាស្រ័យហេតុនេះទោះបីមិនឃើញថាមានសភាពធ្ងន់ធ្ងរយ៉ាងណាក៏ដោយត្រូវតែទៅរកវេជ្ជបណ្ឌិតព្យាបាលដាច់ខាត
- ជាតិគីមីដូចជា៖ អាស៊ីដ ឬ ទឹកក្បុងអាចឱ្យរលាកយ៉ាងឆាប់រហ័ស និង ធ្ងន់ធ្ងរទៀតផង
- បើវត្ថុធាតុរាវនោះខ្ទាតទៅលើភ្នែក ឬ ទៅលើខ្លួនប្រាណរបស់អ្នក នោះអ្នកត្រូវលាងទឹកចោលភ្លាម ។ ទឹកផ្កាឈូក និង ទឹកបាញ់លាងភ្នែកត្រូវស្ថិតនៅជិតកន្លែងធ្វើការបំផុត ។

៨. របួសភ្នែក



- ធូលីនៅក្នុងភ្នែក គឺជាការឈឺចាប់ជាទូទៅ ប្រសិនបើសម្រាមចូលភ្នែកអ្នកហើយ វាស្ថិតនៅសើៗខាងលើ នោះអ្នកអាចយកវាចេញភ្លាមដោយលាងដៃនឹងទឹក ឬ ផ្តិតដោយប្រើសំឡីសើមៗ ឬ ប្រើចុងជ្រុងកន្សែងដៃស្អាតក៏បាន
ជាតិអាកាឡាំង អាស៊ីដ នៅក្នុងភ្នែកអាចបណ្តាលឱ្យឈឺចាប់យ៉ាងខ្លាំង អ្នកត្រូវលាងភ្នែកនឹងទឹកភ្លាម យ៉ាងហោចណាស់ក៏រយៈពេល ១០ នាទីដែរ ក្រោយលាងរួចហើយ អ្នកត្រូវទៅឱ្យគ្រូពេទ្យពិនិត្យមើលជាបន្ទាន់ ។

## ៩. របួសដោយសារអគ្គិសនី



- ការឆក់ដោយអគ្គិសនី ប៉ះពាល់ទៅលើបេះដូង ហើយអាចបណ្តាលឱ្យស្លាប់ភ្លាមៗ ។ អ្នកត្រូវអគ្គិសនីឆក់ត្រូវរងគ្រោះបន្ថែម ដោយសារការភ្ញាក់ធ្លាក់ពីលើរន្ទាជណ្តើរ ឬ ពីលើទីកន្លែងខ្ពស់
- ប្រសិនបើជនរងគ្រោះនៅតែប៉ះជាប់នឹងគ្រឿងប្រដាប់អគ្គិសនី ត្រូវកាត់ចរន្តដោយបិទកុងតាក់ ឬ ប្រភពអគ្គិសនីភ្លាម។ ប្រសិនបើមិនអាចបិទបានទេនោះ ត្រូវប្រើប្រាស់វត្ថុណាដែលវែងស្ងួត ស្អាត និង មិនចំលងភ្លើងដើម្បីទាញជនរងគ្រោះចេញឱ្យឆ្ងាយពីកន្លែងឆក់
- នៅពេលជនរងគ្រោះត្រូវបានទាញចេញឆ្ងាយពីកន្លែងឆក់រួចហើយ ត្រូវធ្វើចលនាសួត បេះដូងប្រសិនបើចាំបាច់ ។ កុំខាតពេលវេលា និង យកជនរងគ្រោះទៅកន្លែងដទៃទៀត។តាមក្បួនច្បាប់គេមិនត្រូវព្យាបាលស្នាមរលាកដោយសារអគ្គិសនីឡើយ។

## ១០. ការបាក់អវៈយវៈ ការគ្រេច ការភ្លាត់ឆ្អឹង



- ក្នុងករណីមានសង្ស័យថាមានបាក់ឆ្អឹងអវៈយវៈត្រង់កន្លែងណាមួយ ជនរងគ្រោះត្រូវដាក់ឱ្យនៅនឹងមួយកន្លែង កុំបីកំរើកឱ្យសោះ ដើម្បីការពារការបាក់កាន់តែធ្ងន់ធ្ងរឡើងថែមទៀត និង ដើម្បីបន្ថយការឈឺចាប់ផង ។ ត្រូវរណបអបឆ្អឹងដែលបាក់ដោយដំបងឈើពីរ ឬ ក៏យកក្រដាសកាសែតមករុំព័ទ្ធដាក់ទម្រណបនៅខាងក្រៅសម្លៀកបំពាក់ ហើយយកក្រណាត់រុំបន្ថែមមួយជាន់ពីលើទៀត។ រណប ឬ ទម្រអាចឱ្យវែងបន្តិច ដើម្បីអាចទប់ពីលើពីក្រោមកន្លែងដែលឆ្អឹងត្រូវបាក់គ្រេចភ្លាត់នោះ។ដើម្បីជៀសវាងការសង្កត់ដោយមិនបាច់ទៅលើកន្លែងបាក់នោះ គេអាចដាក់សំឡីនៅចន្លោះគ្រឿងរណប និង អវៈយវៈ ។
- នៅក្នុងករណីបាក់ដៃ ឬ ជើង ចូរកុំឱ្យរបួសកាន់តែធ្ងន់ធ្ងរទៀត ដោយការរឹតបន្តឹងអវៈយវៈដែលបាក់នោះ ។ រូបគំនូរខាងក្រោមនេះ បង្ហាញពីរបៀបលើកដាក់ក៏សមស្របមនុស្សដែលបាក់ជើង។
- ជើងបាក់ត្រូវទ្រដោយរុំភួយទាំងសងខាងដើម្បីបន្ថយចលនានៅកន្លែងបាក់ ។

គ្រប់កន្លែងធ្វើការ និង ក្រុមហ៊ុនទាំងអស់ត្រូវតែមានគំរោងផែនការ និង ការរៀបចំដឹកជញ្ជូនឱ្យបានឆាប់រហ័សទៅកាន់មន្ទីរពេទ្យ និង ព្យាបាលរាល់របួសទាំងអស់ដែលអាចកើតឡើងដោយថាហេតុ ។

១១. របួសលលាដ៏ក្បាល និង ឆ្អឹងខ្នង





- ការប៉ះទង្គិចខ្លាំងទៅលើលលាដ៏ក្បាលនាំឱ្យសន្លប់ និង របួសដល់ឆ្អឹងខ្នង
- បើមនុស្សម្នាក់នៅមានដង្ហើម និង នៅដឹងខ្លួននៅឡើយកុំឱ្យគេកំរើក លើកលែងតែត្រូវការបញ្ចេញខ្យល់ឱ្យបានស្រឡះ
- ក្នុងករណីនេះត្រូវប្រយ័ត្នកុំឱ្យរបួសដល់ឆ្អឹងខ្នង ដោយដាក់ឱ្យគេដេកផ្អៀងយកមុខចុះក្រោម
- ក្នុងជំហរបែបនេះ បងប្អូនត្រូវការពារកុំឱ្យឈាមដែលចេញពីមុខរបួសណាមួយក្នុងមាត់ ឬបំពង់ក រត់ចូលទៅក្នុងបំពង់សួតបាន ។
- ដាច់ខាតកុំញុកសំឡីទៅក្នុងរន្ធច្រមុះជនរងគ្រោះដើម្បីការពារ ការហូរឈាមឱ្យសោះ ។ កាលណាបើមានឈាមហូរតាមត្រចៀក សូមកុំលាងឈាមនោះចេញឱ្យសោះ ។ ប្រសិនបើជនរងគ្រោះសន្លប់ ហើយរឹងថ្គាមសូមកុំសាកល្បងគាស់បើកមាត់ឱ្យសោះ ។
- សូមកុំព្យាយាមឱ្យអ្វីទៅមនុស្សសន្លប់ផឹកឱ្យសោះព្រោះវាអាចឱ្យវត្ថុរាវនោះហូរចូលទៅក្នុងបំពង់ដកដង្ហើម និង សួតជាហេតុបណ្តាលឱ្យស្ទះខ្យល់ទៅវិញទេ ។
- នៅពេលណាមានការសង្ស័យថាជនរងគ្រោះត្រូវបាក់ឆ្អឹងខ្នង ឬ ឆ្អឹងត្រគាកគឺមានតែបុគ្គលិកដែលមានការបណ្តុះបណ្តាលទើបអាចលើកជនរងគ្រោះបាន ។

១២. របួសនៅពោះ

- បើរបួសនៅពោះបណ្តាលមកពីការប៉ះទង្គិច ឬ ក៏មានវត្ថុអ្វីមួយធ្លាក់មកលើមនុស្ស ។ល។ នោះជនរងគ្រោះត្រូវតែនាំទៅមន្ទីរពេទ្យជាបន្ទាន់ ។
- ហាមឱ្យជនដែររងរបួសហូប ឬ ផឹកទឹកអ្វីទាំងអស់
- របួសបើកមុខត្រូវគ្របឱ្យជិតដោយប្រើក្រណាត់ស្បៃស្អាត និង សើម ។ ពេលដឹកទៅមន្ទីរពេទ្យត្រូវថែទាំជនរងគ្រោះឱ្យមែនទែន ។

១៣. ការលើកមនុស្ស



- នៅពេលជនរងរបួសត្រូវរងចាំរថយន្តពេទ្យ ត្រូវដាក់ជននោះនៅកន្លែងសុវត្ថិភាព ហើយរបៀបលើកដែលសមស្របបំផុតគឺត្រូវប្រើប្រាស់គ្រែស្នែង ឬ ភួយធំមួយ
- ដើម្បីជួយសង្គ្រោះជនរងគ្រោះឱ្យបានឆាប់រហ័សពីកន្លែងកើតហេតុនៅក្នុងករណីគ្រោះថ្នាក់ដោយភ្លើងឆេះវិធីដ៏ល្អបំផុតគឺចាប់អូសយកជននោះចេញដោយចាប់ទាញសម្លៀកបំពាក់របស់គេ
- ប្រសិនបើបងប្អូននៅម្នាក់ឯង ហើយត្រូវការជំនួយមិត្តភក្តិដោយយកគេចេញយ៉ាងឆាប់រហ័សពីកន្លែងគ្រោះថ្នាក់ ។ ការលើកដូចខាងក្រោមនេះ គឺជាវិធីងាយស្រួល និង ល្អបំផុតដែលត្រូវប្រើ ។

✓ **អគ្គិភ័យ**

១. វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់ (ច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ)

- អគ្គិភ័យសំដៅដល់ករណីមានភ្លើងឆេះមិនអាចគ្រប់គ្រងបានដែលអាចបង្កមហន្តរាយដល់អាយុជីវិត ទ្រព្យសម្បត្តិ និង បរិស្ថាន ។
- ការបង្ការអគ្គិភ័យ សំដៅដល់ការរៀបចំអនុវត្តនូវលក្ខខណ្ឌ និងវិធានការនានាដើម្បីធានាសុវត្ថិភាព មិនឱ្យបានអគ្គិភ័យកើតឡើង ។
- ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ សំដៅដល់ការបំពាក់ឧបករណ៍បច្ចេកទេសក្នុង និង/ឬក្រៅគោលដៅ និងវិធានការនានាដើម្បីបង្ការទប់ស្កាត់ ពន្លត់អគ្គិភ័យ និងសង្គ្រោះ ។
- មធ្យោបាយ សំដៅដល់យានយន្ត ឧបករណ៍ សម្ភារៈ បរិក្ខារដែលប្រើប្រាស់សម្រាប់បង្ការ និង ពន្លត់អគ្គិភ័យ ។
- ទីកន្លែងងាយឆេះ ឬ ងាយផ្ទុះឆេះ សំដៅដល់ទីកន្លែងដែលមានស្តុក ប្រើប្រាស់សារជាតុងាយឆេះ ឬ ងាយផ្ទុះឆេះ ។
- សារជាតុងាយឆេះ ឬងាយផ្ទុះឆេះ សំដៅដល់សារជាតុរាវ រឹង ឧស្ម័ន គីមី ទំនិញ ឬ វត្ថុធាតុដើមដែលងាយឆេះ ឬ ងាយផ្ទុះឆេះ ។
- ការពន្លត់អគ្គិភ័យ សំដៅដល់ការពន្លត់អគ្គិភ័យ និង ទប់ស្កាត់ការឆេះរាលដាលដោយប្រើប្រាស់កម្លាំង ប្រើប្រាស់មធ្យោបាយពន្លត់អគ្គិភ័យ និងប្រើប្រាស់គ្រប់វិធានការផ្សេងៗទៀត ។

- តំបន់ពន្លត់អគ្គិភ័យ សំដៅដល់ទីកន្លែងកំពុងឆេះ ឬប្រឈមនឹងការឆេះដែលសមត្ថកិច្ចកំពុងប្រតិបត្តិការពន្លត់អគ្គិភ័យ ។
- គោលដៅ សំដៅដល់ទីកន្លែងនានា និងមធ្យោបាយដឹកជញ្ជូនទាំងឡាយដែលអាចមានអគ្គិភ័យកើតឡើង ។

២. មូលហេតុដែលបង្កឱ្យមានភ្លើងឆេះជាញឹកញាប់

- មនុស្សដែលធ្វើការជាមួយភ្លើង ដូចជាចុងភៅ ជាងផ្សារ ឬ អ្នកប្រកបការងារជាមួយសារធាតុដែលងាយឆេះ ការជក់បារីចោលស្រេចនឹងចិត្ត ការតខ្សែភ្លើងអគ្គិសនីមិនបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសធ្វើឱ្យឆ្លង ឬ ប៉ះគ្នាបង្កបណ្ដាលឱ្យចេញផ្កាភ្លើង ឬខ្ទាតផ្កាភ្លើងចេញពីក្បាលរថភ្លើង ។ល។
- បញ្ហាធម្មជាតិ ដូចជាព្រៃឈើ ស្លឹកឈើ ដែលរងកំដៅខ្លាំង ហើយមានភាពស្ងួតខ្លាំង បាតុភូត រន្ទះបាញ់ ផ្ទុះភ្នំភ្លើង ។ល។

៣. បំពង់ពន្លត់អគ្គិភ័យ

**ក. Dry chemical fire extinguishers ចែកជា៣ប្រភេទ ៖**

ក.១. បំពង់សុវត្ថិភាពពន្លត់អគ្គិភ័យធម្មតា Sodium bicarbonate មានប្រសិទ្ធិភាពប្រើប្រាស់តែ Class B and C ប៉ុណ្ណោះទេ វាធ្វើឱ្យខូចគុណភាពរបស់ដែលត្រូវភ្លើងឆេះនោះតិចជាងប្រភេទបំពង់ពន្លត់អគ្គិភ័យផ្សេងៗទៀត Class B ប្រេងថ្នាំលាប... Class C ខ្សែភ្លើងដែលឆ្លងប៉ះគ្នាធ្វើឱ្យភ្លើងឆេះធម្មតា ។

ក.២. Ammonium phosphate វាមានប្រសិទ្ធិភាព សំរាប់ class A,B,C ភាគច្រើន គេប្រើវាតែ Class A មួយគត់ (ឈើ ក្រដាស សំរាម ក្រណាត់...)

ក.៣. Perpurple K or Potassium Bicarbonate សម្រាប់ប្រើនៅពេលដែលភ្លើងឆាបឆេះខ្លាំងជាងធម្មតា វាធ្វើឱ្យខូចសំភារៈដែលឆេះនោះច្រើនជាងប្រភេទបំពង់ពន្លត់អគ្គិភ័យផ្សេងៗទៀត តែគេទុកវាសម្រាប់ប្រើតែ Class B and C ។

**ខ.** ១. $CO_2$ fire extinguishers វាមានកម្លាំងបាញ់ចេញខ្លាំងជាងទឹកធម្មតាពេលបាញ់ចេញ ភ្លាមស្ងួតភ្លាម សម្រាប់ប្រើពន្លត់លើរបស់បរិក្ខារអេឡិចត្រូនិច ប្រើសម្រាប់ Class B and C ។ បំពង់ប្រភេទនេះ វាកាត់បន្ថយអុកស៊ីសែននៅកន្លែងហប់តូចចង្អៀត គេមិនត្រូវប្រើវាទេ ។

**ខ.** ២. Class D fire extinguisher divise in 2 ៖

a. Sodium chloride កាត់បន្ថយកំដៅលោហធាតុដែលឆេះ ដូចជា Magnesium, potassium, Uranium Alumium powder

b. ម្សៅស្ងួត មានជាតិស្ពាន់ កាត់បន្ថយកំដៅនៅរបស់ដែលកំពង់ឆេះ ធ្វើឱ្យភ្លើងរលត់ភ្លាម សម្រាប់ប្រើរបស់ ដែលឆេះដូចជា Lithium ។

គ. Class K fire extinguisher ខ្លាញ់ ប្រេងឆា... ។

| Comparison of fire classes | | | |
|---|---|---|---|
| **American** | **European** | **Australasian** | **Fuel/Heat source** |
| Class A | Class A | Class A | Ordinary combustibles |
| Class B | Class B | Class B | Flammable liquids |
| | Class C | Class C | Flammable gases |
| Class C | Class F/D | Class E | Electrical equipment |
| Class D | Class D | Class D | Combustible metals |
| Class K | Class F | Class F | Cooking oil or fat |

Choosing Fire Extinguishers

Identify the type of materials in the area

Class A: SOLIDS such as paper, wood, plastic etc

Class B: FLAMMABLE LIQUIDS such as paraffin, petrol, oil etc

Class C: FLAMMABLE GASES such as propane, butane, methane etc

Class D: METALS such as aluminium, magnesium, titanium etc

Class E: Fire involving ELECTRICAL APPARATUS

Class F: Cooking OIL & FAT etc

៤. វិធានការណ៍ការពារនឹងទប់ទល់ពេលមានបំពង់ពន្លត់អគ្គិភ័យ

ក. វិធានការណ៍ការពារ

- រោងចក្រត្រូវធ្វើការសាកល្បងដល់កម្មករទាំងអស់យ៉ាងហោចណាស់ក៏១ឆ្នាំឱ្យបាន១ដងដែរនូវវិធានការណ៍ចាកចេញពីរោងចក្រជាបន្ទាន់នៅពេលឮកណ្ដឹងប្រកាសអាសន្ន ។
- ត្រូវបង្រៀនកម្មករនិយោជិតទាំងអស់ឱ្យចេះពីរបៀបប្រើប្រាស់បំពង់ពន្លត់អគ្គិភ័យ នៅពេលមានភ្លើងឆេះធម្មតា ពួកគេអាចជួយបាន ។
- អ្នកគ្រប់គ្រង ឬ អ្នកទទួលខុសត្រូវទាំងអស់ត្រូវចេះរបៀបប្រើបំពង់ពន្លត់អគ្គិភ័យ នឹងជាអ្នកនាំកម្មករចាកចេញពីរោងចក្រនៅពេលមានភ្លើងឆេះ ។
- ត្រូវបង្រៀនអ្នកធ្វើការទាំងអស់ឱ្យយល់ពីមូលហេតុ នឹងស្គាល់ពីសារធាតុដែលងាយឆេះ ។

ខ. ចំណុចដែលត្រូវត្រួតពិនិត្យ

- តើនៅកន្លែងធ្វើការមានបិទ នឹងធ្វើការផ្សព្វផ្សាយស្ដីពីនីតិវិធី ដែលត្រូវអនុវត្តជាចាំបាច់នៅពេលមានអគ្គិភ័យកើតឡើងឬទេ ?
- តើកម្មករនិយោជិតទាំងអស់យល់ដឹង នឹងចេះអនុវត្តតាមនីតិវិធីដែលបានបង្ហាត់បង្រៀនឬទេ ?
- តើរោងចក្រមានបានធ្វើការសាកល្បងតាមកាលកំណត់ដែលឬទេ ?
- តើទ្វារសម្រាប់ចាកចេញមានគ្រប់គ្រាន់នឹងមានភាពងាយស្រួលដែរទេ ?

- តើទ្វារសម្រាប់ចាកចេញមានដាក់សញ្ញា ឬ ភ្លើងសំគាល់ឬទេ ?
- តើបំពង់ពន្លត់អគ្គិភ័យដែលដាក់តាមផ្នែក មានដាក់តាមក្រុមសម្រាប់ពន្លត់របស់ដែលត្រូវឆេះឬទេ ?
- តើបំពង់ពន្លត់អគ្គិភ័យមានគ្រប់គ្រាន់ឬទេ ?
- តើមានសញ្ញាបង្ហាញពីកន្លែងដាក់បំពង់ពន្លត់អគ្គិភ័យឬទេ ?
- តើបំពង់ពន្លត់អគ្គិភ័យដែលដាក់ជាប់ជញ្ជាំង មានផ្លូវស្រឡះនឹងងាយស្រួលយកមកប្រើប្រាស់ឬទេ ?
- តើមានបានសាកល្បង បញ្ជាក់ថាបំពង់ពន្លត់អគ្គិភ័យទាំងអស់សុទ្ធតែប្រើបានឬទេ ?
- តើបំពង់ពន្លត់អគ្គិភ័យ បានត្រួតពិនិត្យនឹងថែរក្សាជាប្រចាំបានល្អឬទេ ?
- តើមានផែនទីបង្ហាញពីកន្លែងទុកបំពង់ពន្លត់អគ្គិភ័យឬទេ ?
- តើបំពង់ពន្លត់អគ្គិភ័យត្រូវមានពណ៌បញ្ជាក់ពីប្រភេទនៃបំពង់ពន្លត់អគ្គិភ័យដែលឬទេ ?
- ត្រួតពិនិត្យមើលសារធាតុដែលងាយឆេះ ត្រូវដាក់ឱ្យដាច់ពីគ្នា នឹងឱ្យឆ្ងាយពីរបស់ផ្សេងៗទៀត ។
- ត្រូវកាត់បន្ថយនាំចូលសារធាតុដែលងាយឆេះ ក្នុងម៉ោងធ្វើការ ។
- ត្រូវចេះសំអាតកន្លែងធ្វើការឱ្យបានស្អាតជានិច្ច ជាពិសេសកន្លែងដែលបង្កឱ្យឆេះ ព្រោះកន្លងមកបញ្ហាដែលបណ្តាលឱ្យឆេះតែងមានកើតឡើងជាដដែលៗ ។
- តើមានផែនការចាកចេញពីរោងចក្រ ទៅតាមជាន់របស់វាដែលឬទេ ?

៥. នីតិវិធីដែលត្រូវអនុវត្ត ជាបន្ទាន់នៅពេលមានអគ្គិភ័យកើតឡើង

- ពេលមានភ្លើងឆេះកើតឡើង តើយើងត្រូវធ្វើដូចម្តេច ?
- កុំឱ្យភ័យស្លន់ស្លោរ ឬរត់ឆ្វេរឆ្វា ឬស្រែកផ្អើលឆោឡោឱ្យសោះ ។
- ភ្លាមៗ ត្រូវចុចកណ្តឹងប្រកាសអាសន្នដែលនៅជិត (ប្រអប់ពណ៌ក្រហម) ។
- ទូរស័ព្ទទៅភ្នាក់ងារពន្លត់អគ្គិភ័យ ប្រាប់ឈ្មោះ ទីកន្លែងឱ្យបានច្បាស់លាស់ បើអាចប្រាប់បានត្រូវប្រាប់ពីមូលហេតុ នៃភ្លើងឆេះ តើឆេះរបស់អ្វីខ្លះ ឆេះមានទំហំតូច ឬធំ តើរាលដាលលឿនឬទេ ?
- បើមានភ្លើងឆេះ ទំហំ ឬ ទ្រង់ទ្រាយតូច បើអាចពន្លត់បានត្រូវពន្លត់ភ្លាមដោយមិនបាច់ទូរស័ព្ទ ហើយបើប្រើអស់ ១បំពង់មិនរលត់ ត្រូវទូរស័ព្ទភ្លាម ។
- ត្រូវរត់ចេញពីអគារភ្លាមតាមសញ្ញាសុវត្ថិភាព នឹងតាមទ្វារដែលនៅក្បែរ បើអាចធ្វើបានត្រូវទ្វារបន្ទប់ដែលឆេះ មុនរត់ចេញ ។

៦. សកម្មភាពពេលឮកណ្តឹងប្រកាសអាសន្ន

- កុំឱ្យភ័យស្លន់ស្លោរ ឬ រត់ឆ្វេរឆ្វា នាំឱ្យផ្អើលដល់គេទាំងអស់គ្នា ។

- ដើរចេញក្លាម តាមទ្វារដែលនៅក្បែរ ដោយយករបស់សំខាន់ជាប់មកជាមួយ ត្រូវដើរតាមសញ្ញាសុវត្ថិភាព មិនត្រូវរត់ឆ្វេងឆ្វាឡើយ ។ បើនៅជាន់លើត្រូវចុះតាមកាំជណ្តើរហាមចុះតាមជណ្តើរយន្តត្រូវបិទទ្វារបន្ទប់ ដែលឆេះមុនចាកចេញបើអាចធ្វើទៅបាន ។
- ត្រូវធ្វើតាមបញ្ជា ភ្នាក់ងារពន្លត់អគ្គិភ័យ ។
- កាលណាឮកណ្តឹងត្រូវដឹងថាជាកណ្តឹង ប្រកាសអាសន្នមែនទែន រួចត្រូវធ្វើតាមនីតិវិធីដែលគេធ្លាប់បានសាកល្បង កន្លងមកដោយចាកចេញភ្លាមៗហាមចុះតាមជណ្តើរយន្ត ។
- ត្រូវដើរតៗគ្នា មិនត្រូវរត់ ឬប្រជែងគ្នាចេញឡើយ គឺត្រូវដើរចេញតាមលំដាប់លំដោយចំពោះអ្នកដែលចេញក្រោយគេ បើអាចធ្វើបានត្រូវបិតទ្វារបន្ទប់ឆេះមុនចាកចេញ ។
- កំពុងតែដើរ បើមានដុំភ្លើងឆេះ ធ្លាក់ពីលើចំពីមុខ ត្រូវដើរវាងទៅផ្លូវផ្សេងភ្លាម ។
- ពេលចេញផុតពីអគារ ត្រូវដើរទៅឱ្យឆ្ងាយពីអគារ ទុកកន្លែងឱ្យអ្នកដែលដើរមកពីក្រោយយើង ។
- បើអាចសង្គ្រោះបាន សូមជួយសង្គ្រោះជនពិការ ឬ អ្នកដែលត្រូវរបួសផង ។
- កុំចូលទៅក្នុងអគារវិញដាច់ខាត ទោះជាមានការបាច់យ៉ាងណាក៏ដោយរហូតដល់មានបញ្ជាពីអ្នកពន្លត់អគ្គិភ័យ ទើបអាចចូលបាន ។
- ពេលលែងឮកណ្តឹងរោទិ៍ប្រកាសអាសន្ន កុំដើរចូលមកក្នុងអគារវិញឱ្យសោះ ។

- ផ្ទាំងរបបអាហារទាំងបីក្រុម

★ រូបភាពផ្ទាំងរបបអាហារទាំងបីក្រុម









- ពាក្យស្លោកអប់រំ

★ ផ្ទាំងពាក្យស្លោកអប់រំ




































- ខិត្តប័ណ្ណ

★ រូបភាពខិត្តប័ណ្ណអប់រំ



- ស្តួតអប់រំស្តីពីៈ
  - អត្ថប្រយោជន៍របបសន្តិសុខសង្គម
  - របបអាហារទាំងបីក្រុម
  - ការងារថែមម៉ោង
  - ការបង្ការគ្រោះថ្នាក់ចរាចរណ៍របស់កម្មករនិយោជិត
  - ណែនាំពីបច្ចេកទេសថែទាំយានយន្ត
  - សារសំខាន់នៃបណ្ណបើកបរ

✓ **អំពីកិច្ចប្រជុំផ្សព្វផ្សាយអប់រំ ក្នុងឆ្នាំ២០១៤**

អនុលោមតាមអនុសាសន៍របស់ **ឯកឧត្តមរដ្ឋមន្ត្រី** ក្រសួងការងារ និង បណ្តុះបណ្តាល វិជ្ជាជីវៈ ក្នុងឱកាសបើកពិធីប្រជុំបូកសរុបលទ្ធផលការងាររបស់គណៈកម្មការស.ទ.ប.ក និង បើកពិធី ប្រជុំបូកសរុបលទ្ធផលការងាររបស់ ប.ស.ស ឆ្នាំ២០១៣ និង ទិសដៅអនុវត្តបន្តឆ្នាំ២០១៤ ជាមួយនឹងការយកចិត្តទុកដាក់ពីលោកនាយក ប.ស.ស ។ គណៈកម្មការស.ទ.ប.ក នៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយនឹង ប.ស.ស បន្តរៀបចំកិច្ចប្រជុំផ្សព្វផ្សាយអប់រំដូចភ្លៀងរលឹម ដើម្បីឱ្យនិយោជក ឬ តំណាងសហគ្រាស គ្រឹះស្ថាន និង កម្មករនិយោជិតទទួលបាននូវចំណេះដឹង ស្តីពី លក្ខខណ្ឌការងារ, លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ (ការទប់ស្កាត់កម្មករនិយោជិតសន្លប់), អត្ថប្រយោជន៍នៃការអនុវត្តរបបសន្តិសុខសង្គម និង ការបង្ការគ្រោះថ្នាក់ចរាចរណ៍របស់កម្មករនិយោជិត ក្នុងន័យទប់ស្កាត់ និង បង្ការគ្រោះថ្នាក់ការងារ ពិសេសការចូលរួមកាត់បន្ថយកម្មករនិយោជិតសន្លប់ឱ្យស្ថិតនៅកំរិតក្បែរសូន្យ ។

ទោះបីការកើនឡើងចំនួនរោងចក្រកាត់ដេរ និង ផលិតស្បែកជើង ដល់ចំនួន ១,០៧៥ រោងចក្រ និង កម្មករនិយោជិត ក៏កើនដល់ចំនួន ៦៩៩,១៥៨ នាក់ គឺស្របនឹងការកើនឡើងនេះ ចំនួនរោងចក្រក្នុងឆ្នាំ២០១៤នេះ បានរងការសន្លប់ ៣៤ រោងចក្រ និង កម្មករនិយោជិត ១,៨០៦ នាក់ ។

តាមការវិភាគរកឃើញថា បញ្ហាគីមី, បញ្ហារូបសាស្ត្រ, បញ្ហាចិត្តសាស្ត្រ និង បញ្ហាថែមម៉ោង ក្នុងចំណោមបញ្ហាទាំងប្រាំពីរ គឺជាដើមហេតុដែលបណ្តាលឱ្យកម្មករនិយោជិតសន្លប់ ។ ដូចនេះ ករណីកម្មករនិយោជិតសន្លប់ មកពីបរិយាកាសក្នុងអាគារមានខ្យល់ចេញចូលមិនគ្រប់គ្រាន់ ការប្រើប្រាស់សារធាតុគីមីមិនត្រឹមត្រូវតាមលក្ខខណៈបច្ចេកទេស បូករួមនឹងការបន្ថែមម៉ោងច្រើន និង កត្តាកម្មករនិយោជិតរងសំពាធពីខាងក្នុង និង ក្រៅ ជាដើម ។

ទន្ទឹមនឹងនេះ ការផ្សព្វផ្សាយអប់រំនៅក្នុងឆ្នាំ២០១៤ នេះ ក៏បានរៀបចំចំនួន ១៩ លើក ស្មើនឹង ២៧ រោងចក្រ និង កម្មករនិយោជិតចូលរួមប្រមាណជា ៣,១០០ នាក់ (និយោជក/តំណាងនិយោជក/រដ្ឋបាល, តំណាងសហជីពមូលដ្ឋាន, ប្រតិភូបុគ្គលិក, ប្រធានក្រុម/ផ្នែក, កម្មករនិយោជិត និង គ្រូពេទ្យគិលានដ្ឋាន និង សន្តិសុខរោងចក្រ ) ដែលមានទីតាំង និង កាលបរិច្ឆេទ លំអិតខាងក្រោម ៖

១- ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៤ នៅរោងចក្រ CAMBO KOTOP LTD មានទីតាំងស្ថិតភូមិកន្ទោក សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

២- ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ នៅរោងចក្រ SHOE PREMIER II (CAMBODIA) CO., LTD មានទីតាំងស្ថិតសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

៣- ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤ នៅរោងចក្រ NEW ORIENT (CAMBODIA) GARMENT CO., LTD មានទីតាំងស្ថិតសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

៤- ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ នៅរោងចក្រ YAZAKI (CAMBODIA) PRODUCTS CO., LTD និង រោងចក្រ KKN APPAREL CO.,LTD មានទីតាំងស្ថិត នៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសេមា ខេត្តកោះកុង ។

៥- ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ នៅសួនឧស្សាហកម្មវឌ្ឍនៈ II (មាន០៨ រោងចក្របានឱ្យកម្មករចូលរួម) មានទីតាំងស្ថិតតាមបណ្តោយផ្លូវជាតិលេខ៣ ។

៦- ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ នៅរោងចក្រ BERRY APPAREL CAMBODIA) CO., LTD មានទីតាំងស្ថិតស.ចោមចៅ ខ.សែនជ័យ រាជធានីភ្នំពេញ ។

៧- ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ នៅរោងចក្រ M & V International Manufacturing Ltd មានទីតាំងស្ថិតស.ចាក់អង្រែក្រោម ខ.មានជ័យ រាជធានីភ្នំពេញ ។

៨- ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៤ នៅរោងចក្រ KING FIRST INDUSTRIAL CO., Ltd មានទីតាំងស្ថិតនៅឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល ។

៩- ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤ នៅរោងចក្រ YORKS (CAMBODIA) CO., LTD មានទីតាំងស្ថិតនៅឃុំបាវិត ស្រុកចន្ទ្រា ខេត្តស្វាយរៀង ។

១០- ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៤ នៅរោងចក្រ A and J (CAMBODIA) CO., Ltd មានទីតាំងស្ថិតនៅតំបន់សេដ្ឋកិច្ចពិសេសតាយសេង ខេត្តស្វាយរៀង ។

១១- ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៤ នៅរោងចក្រ ELITE (CAMBODIA) CO., Ltd មានទីតាំងស្ថិតនៅឃុំបាទី ស្រុកបាវិត ខេត្តស្វាយរៀង ។

១២- ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៤ នៅរោងចក្រ CALLISTO APPAREL (CAMBODIA) CO., LTD មានទីតាំងស្ថិតនៅភ.ស្រែរាជ ស.សំរោងក្រោម ខ.ពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

១៣- ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៤ នៅរោងចក្រ New Wide (Cambodia) Garment Co.,Ltd មានទីតាំងស្ថិតនៅភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

១៤- ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ នៅរោងចក្រ DAQIAN TEXTILE (CAMBODIA) CO.,LTD មានទីតាំងស្ថិតនៅភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

១៥- ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ នៅរោងចក្រ COCOVOL APPAREL (CAMBODIA) CO., LTD មានទីតាំងស្ថិតនៅភូមិព្រៃព្រីងខាងត្បូង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

១៦- ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ នៅរោងចក្រ SHENZHOU (CAMBODIA) CO.,LTD មានទីតាំងស្ថិតនៅភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ។

១៧- ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ នៅរោងចក្រ New Star Shoes CO.,LTD មានទីតាំងស្ថិតនៅសង្កាត់លេខ១ សង្កាត់មិត្តភាព ខេត្តព្រះសីហនុ ។

១៨- ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤ នៅរោងចក្រ E Garment CO.,LTD មានទីតាំងស្ថិតនៅឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល ។

១៩- ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៤ នៅរោងចក្រ WINSAND GARMENT & WOOLEN KNITTING FACTORY CO.,LTD មានទីតាំងស្ថិតនៅឃុំព្រែកដាច់ ស្រុកលើកដែក ខេត្តកណ្តាល ។

## ខ. បញ្ហាប្រឈម

### ❖ កត្តាកម្មករនិយោជិត

- ធ្វើការថែមម៉ោងច្រើនលើសពីការអនុញ្ញាតរបស់ក្រសួង បានធ្វើឱ្យសុខភាពចុះខ្សោយ
- បរិភោគអាហារមិនមានជីវជាតិ កង្វះអនាម័យ ហើយជួនកាលខកខានបរិភោគអាហារទៀត
- សម្រាកមិនបានគ្រប់គ្រាន់
- មានស្ថានភាពតានតឹងក្នុងអារម្មណ៍

### ❖ កត្តានិយោជក

- រោងចក្រមួយចំនួនមិនព្រមចូលរួមសហការរាយការណ៍ចំនួនកម្មករនិយោជិតពិតប្រាកដមកឱ្យ ប.ស.ស នោះឡើយ
- រោងចក្រមួយចំនួនឱ្យកម្មករនិយោជិតថែមម៉ោងលើសពីការអនុញ្ញាតរបស់ក្រសួង
- រោងចក្រមួយចំនួនមានបរិយាកាសណ៍កំដៅ ក្តៅ និង ហប់
- ការធ្វេសប្រហែសត្រួតពិនិត្យផ្នែកសុខភាព និង សុវត្ថិភាពការងារជាប្រចាំរបស់និយោជក
- និយោជកបានកែលំអវិធានការរបស់គណៈកម្មការស.ទ.ប.ក មានសភាពយឺតយ៉ាវ

### ❖ កត្តាក្រសួង

- រៀបចំផ្សព្វផ្សាយអប់រំ និង ត្រួតពិនិត្យលក្ខខណ្ឌការងារ លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារតាមបណ្តារោងចក្រកាត់ដេរសំលៀកបំពាក់ និង ផលិតស្បែកជើង នៅពុំទាន់បានឆ្លើយតបទៅនឹងបរិមាណនៃចំនួនរោងចក្រដែលដំណើរការបច្ចុប្បន្ន

- ផ្សព្វផ្សាយការអនុវត្តច្បាប់ស្តីពីការងារ និង ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ នៅតាមបណ្តាសហគ្រាស គ្រឹះស្ថាន មិនទាន់បានទូលំទូលាយនៅឡើយ ។

## គ. ដំណោះស្រាយ

### ❖ ចំពោះមុខ

- បញ្ជាឱ្យរោងចក្រដែលមានគ្រោះថ្នាក់ ផ្អាកការងារជាបណ្តោះអាសន្ន
- ចាត់មន្ត្រីជំនាញជួយសង្គ្រោះ និង តាមដានឃ្លាំមើលសភាពកម្មករនិយោជិតនៅនឹងកន្លែងគ្រោះថ្នាក់ទាន់ពេលវេលានិងជាប់ជាប្រចាំរហូតដល់កន្លែងធ្វើការវិលមកស្ថានភាពប្រក្រតីវិញ
- ទទួលរ៉ាប់រងព្យាបាលដោយឥតគិតថ្លៃដល់ជនរងគ្រោះទាំងអស់ តាមរយៈ ប.ស.ស
- ចាត់វិធានការកែតម្រូវលក្ខខណ្ឌបច្ចេកទេសនានាដែលបានពិនិត្យឃើញថាមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
- ចាត់មន្ត្រីតាមដានពិនិត្យអំពីស្ថានភាពរោងចក្រមុននឹងអនុញ្ញាតឱ្យដំណើរការឡើងវិញ

### ❖ ជាយុទ្ធសាស្ត្រ

- ក្រសួងបានបង្កើតគណៈកម្មការសិក្សាស្រាវជ្រាវទប់ស្កាត់ករណីសន្លប់ និង បង្ការគ្រោះថ្នាក់ការងារ ដែលគណៈកម្មការនេះ មានភារកិច្ចចំបងក្នុងការសិក្សាស្រាវជ្រាវកំណត់ឱ្យបានច្បាស់លាស់នូវមូលហេតុដែលនាំឱ្យមានបាតុភាពសន្លប់ជារួមនៅកន្លែងធ្វើការ និង កំណត់វិធានការបង្ការបានត្រឹមត្រូវ សំដៅធានាការពារសុខមាលភាពកម្មករនិយោជិត
- ក្រសួងបានពង្រឹងបន្ថែមការអនុវត្តច្បាប់ និង បទប្បញ្ញត្តិជាធរមាន ជាពិសេសចំពោះបណ្តារោងចក្រសហគ្រាសកាត់ដេរ និង ស្បែកជើងដែលមានកម្មករនិយោជិតច្រើនជាងវិស័យដទៃផ្សេងទៀត
- រៀបចំយុទ្ធនាការផ្សព្វផ្សាយអប់រំដល់និយោជក និង កម្មករនិយោជិតឱ្យយល់ដឹងពីលក្ខខណ្ឌការងារ លក្ខខណ្ឌអនាម័យសុវត្ថិភាពការងារ ការថែទាំសុខភាព ការការពារបរិស្ថាននៅកន្លែងធ្វើការជាដើម
- ក្រសួងស្នើឱ្យរោងចក្របង្កើតឱ្យមានគណៈកម្មការសុខភាព សុវត្ថិភាពការងារនៅនឹងកន្លែងការងារ

## ឃ. ភារងារអនុវត្តបន្ត

- រៀបចំប្រជុំផ្ទៃក្នុងគណៈកម្មការស.ទ.ប.ក
- រៀបចំចុះតាមរោងចក្រ សហគ្រាសគ្រឹះស្ថាន ដែលមានករណីកម្មករនិយោជិតសន្លប់
- សិក្សាស្រាវជ្រាវមូលហេតុដែលបណ្តាលឱ្យកម្មករនិយោជិតសន្លប់
- រៀបចំផ្សព្វផ្សាយអប់រំតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន
- រៀបចំឯកសារពាក់ព័ន្ធសម្រាប់ផ្សព្វផ្សាយអប់រំ
- អនុវត្តភារកិច្ចផ្សេងៗតាមការប្រគល់ជូនរបស់ថ្នាក់ដឹកនាំ ។

## ខ. សេចក្តីសន្និដ្ឋាន

ក្នុងឆ្នាំ២០១៤ គណៈកម្មការស.ទ.ប.ក ត្រូវបានអនុវត្តការងារឡើង ក្នុងទិសដៅបម្រើកម្មករនិយោជិត ដោយឆន្ទៈទទួលខុសត្រូវខ្ពស់ តាមរយៈការចុះទៅសម្របសម្រួល ពិនិត្យ អង្កេត ស្វែងរកមូលហេតុដ៏ជាក់លាក់ដើម្បីចាត់វិធានការឱ្យនិយោជករោងចក្រ សហគ្រាស គ្រឹះស្ថាន រៀបចំធ្វើការកែលំអបានចំគោលដៅ និង ទាន់ពេលវេលា ។

ទន្ទឹមនឹងនោះ ប.ស.ស ដែលមានគណៈកម្មការស.ទ.ប.ក នៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ បាននិងកំពុងរៀបចំយុទ្ធនាការផ្សព្វផ្សាយអប់រំនៅនឹងកន្លែងការងារនៅតាមបណ្តារាជធានី-ខេត្ត ស្តីពីលក្ខខណ្ឌការងារ លក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ (ការទប់ស្កាត់ករណីកម្មករនិយោជិតសន្លប់) អត្ថប្រយោជន៍នៃការអនុវត្តរបបសន្តិសុខសង្គម និង ការបង្ការគ្រោះថ្នាក់ចរាចរណ៍របស់កម្មករនិយោជិត ក្នុងន័យការពារនិងបង្ការហានិភ័យការងារ (គ្រោះថ្នាក់ការងារ) ។ នៅក្នុងកិច្ចប្រជុំនេះដែរ គ្រូឧទ្ទេសនាមក៏ធ្វើបទបង្ហាញលំអិត និង ចែកជូនកម្មករនិយោជិតនូវឯកសារមេរៀន ខិត្តបណ្ណ ទឹកសុទ្ធ នំប៉័ង និង ប្រាក់ឧបត្ថម្ភ លើពីនោះ ក្រុមការងារបានបិទបង្ហាញបដាពាក្យស្លោក, ផ្ទាំងរូបភាពរបបអាហារ និង សេវាសង្គ្រោះបន្ទាន់ ១២៨៦ ផងដែរ ។

ក្នុងន័យខាងលើ គណៈកម្មការស.ទ.ប.ក និង ប.ស.ស សង្ឃឹមយ៉ាងមុតមាំថា ការផ្សព្វផ្សាយអប់រំនេះ នឹងមានការចូលរួមអនុវត្តរបស់កម្មករនិយោជិត និង និយោជកបានយ៉ាងខ្ជាប់ខ្ជួនជាក់ជាពុំខាន ដែលជាប្រយោជន៍យ៉ាងធំធេង និង ប្រពៃថ្លៃថ្លា ក្នុងការធានាបាននូវ "**សុខដុមរមនានៅកន្លែងការងារកាន់តែប្រសើរឡើង ពិសេសករណីកម្មករនិយោជិតសន្លប់នឹងត្រូវបានកាត់បន្ថយក្នុងកំរិតខ្ពស់**" ៕

## ★ ឯកសារយោង

- ច្បាប់ស្តីពីការងារ
- ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- សេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពគណៈកម្មការសិក្សាស្រាវជ្រាវទប់ស្កាត់ករណីសន្លប់ និង បង្ការគ្រោះថ្នាក់ការងាររបស់កម្មករនិយោជិត
- ផែនការសកម្មភាពរបស់គណៈកម្មការស.ទ.ប.ក ឆ្នាំ២០១៤
- របាយការណ៍បូកសរុបរបស់គណៈកម្មការស.ទ.ប.ក ឆ្នាំ២០១៣ និង ទិសដៅអនុវត្តឆ្នាំ២០១៤
- កំណត់ហេតុចុះរោងចក្ររបស់គណៈកម្មការស.ទ.ប.ក ឆ្នាំ២០១២, ២០១៣ និង ឆ្នាំ២០១៤

## ★ ទំនាក់ទំនងផ្ទាល់

### ១. ប.ស.ស

- លេខទូរស័ព្ទ៖ ០២៣ ៨៨២ ៤៣៤ / ០២៣ ៩៩៨ ៤១៨
  ០២៣ ៩៩៨ ៤១៧ / ០២៣ ៩៩៨ ៤១៩
- លេខទូរសារ៖ ០២៣ ៨៨២ ៦២៣
- គេហទំព័រ (Website)៖ www.nssf.gov.kh
- សារអេឡិចត្រូនិច (E-mail)៖ info@nssf.gov.kh
- **លេខទូរស័ព្ទទំនាក់ទំនងបន្ទាន់** (Hotline) ១២៨៦

### ២.លេខាធិការដ្ឋាន គណៈកម្មការ ស.ទ.ប.ក

- ០១២ ៨៩៨ ៧៨៥ / ០១២ ៩៨៣ ៧១០ / ០១២ ២២៤ ២២២
- ០១២ ៥៧៩ ៤១១ / ០១២ ៧២៣ ៧៣០ / ០១២ ៥០២ ១៤៩
- ០១២ ៧៩០ ៧១២ / ០១២ ៧៩៣ ៥៩៧ / ០៩៧ ២២៥ ២២២២

ស.ទ.ប.ក

២០១៤
























ស.ទ.ប.ក

២០១៥

# សកម្មភាពការងាររបស់ គណៈកម្មការសិក្សាស្រាវជ្រាវទប់ស្កាត់ករណីសន្លប់ និង បញ្ហាគ្រោះថ្នាក់ការងារ (ស.ទ.ប.ក)